# គោលការណ៍ណែនាំ
# ស្ដីពីបរិយាកាស
# ការងារកាន់តែមាន
# សុវត្ថិភាព

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

EUROPEAN UNION

# មាតិកា


I. សេចក្តីផ្តើម ..... ១
១. តើគោលការណ៍ណែនាំនេះ ធ្វើឡើងសម្រាប់នរណា? ..... ២
១. បទប្បញ្ញត្តិទូទៅ ..... ២
២. និយមន័យ អ្នកការពារសិទ្ធិមនុស្ស ..... ៣
២. តើគោលការណ៍ណែនាំនេះ ធ្វើឡើងដើម្បីអ្វី? ..... ៤
៣. ពាក្យគន្លឹះ ..... ៥
៤. តម្រុយដែលមានសារៈប្រយោជន៍ខ្លះៗ ..... ៦
**II. ហានិភ័យដែលអ្នកការពារសិទ្ធិមនុស្សប្រឈម ..... ៧**
១. ការចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើអ្នកការពារសិទ្ធិមនុស្ស និងការបំភិតបំភ័យតាមផ្លូវច្បាប់ **និងតាមផ្លូវរដ្ឋបាល** ..... ៨
១. បទប្បញ្ញត្តិ ..... ៨
២. ផលប៉ះពាល់នៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើអ្នកការពារសិទ្ធិមនុស្ស ..... ៩
៣. ការគំរាមកំហែងដែលអ្នកការពារសិទ្ធិមនុស្សប្រឈម ..... ១១
២. ការដាក់កំហិតលើសេរីភាពសម្តែងមតិ សេរីភាពខាងសមាគម និងសេរីភាពក្នុងការជួបប្រជុំ ..... ១២
១. សេរីភាពសម្តែងមតិ ..... ១២
២. សេរីភាពក្នុងការជួបប្រជុំ ..... ១៣
៣. សេរីភាពខាងសមាគម ..... ១៤
**III. ដំណាក់កាលក្នុងការពង្រឹងសន្តិសុខសុវត្ថិភាពរបស់អ្នកការពារសិទ្ធិមនុស្ស ..... ១៧**
១. វិភាគលើបរិស្ថានរស់នៅ និងបរិស្ថានការងាររបស់អ្នកការពារសិទ្ធិមនុស្ស ..... ២០
២. វាយតម្លៃពីហានិភ័យ ..... ២១
៣. វាយតម្លៃការគំរាមកំហែង និងវិភាគទៅលើឧបទ្ទវហេតុសន្តិសុខសុវត្ថិភាព ..... ២៣
១. ការគំរាមកំហែងមានចរិតលក្ខណៈទូទៅ ..... ២៣
២. ការគំរាមកំហែងដែលមានចរិតលក្ខណៈជាក់លាក់ ..... ២៥
៣. ឧបទ្ទវហេតុសន្តិសុខសុវត្ថិភាព ..... ២៧
៤. ការវាយតម្លៃ និងពង្រឹងសមត្ថភាព ..... ២៩
៥. ការរៀបចំធ្វើផែនការពីសន្តិសុខសុវត្ថិភាព ..... ៣៥
១. តើនឹងត្រូវធ្វើអ្វីខ្លះ នៅពេលអ្នកធ្វើការឲ្យអង្គការ ..... ៣៧
២. តើនឹងត្រូវធ្វើអ្វីខ្លះ នៅពេលធ្វើការជាមួយសហគមន៍ ឬបណ្តាញមូលដ្ឋាន ..... ៣៨
៣. ការធ្វើពង្រាងផែនការ ..... ៣៨
៦. ការអនុវត្ត និងការពិនិត្យឡើងវិញលើផែនការសន្តិសុខសុវត្ថិភាព ..... ៣៩
**IV. ឧទាហរណ៍ ..... ៤០**
១. តារាងឧទាហរណ៍ខាងក្រោមនេះ រៀបរាប់ពីហានិភ័យ ឬភាពងាយរងគ្រោះ ឬកម្រិតសមត្ថភាព តាមក្រុមអ្នកការពារសិទ្ធិមនុស្សនានា ..... ៤២

២. ឧទាហរណ៍នៃការត្រួតពិនិត្យពីសន្តិសុខសុវត្ថិភាពផ្ទាល់ខ្លួន ..................................៤៤
៣. ឧទាហរណ៍ខាងក្រោមនេះ រៀបរាប់ពីការវិភាគលើការគំរាមកំហែងផ្ទាល់ខ្លួន ...........៤៨
៤. ឧទាហរណ៍ខាងក្រោមនេះ គឺជាផែនការការពារសុវត្ថិភាពផ្ទាល់ខ្លួន .......................៤៩
៥. ឧទាហរណ៍ខាងក្រោមនេះ គឺជាកម្រងបញ្ជីត្រួតពិនិត្យ (checklist)
ដែលអ្នកការពារសិទ្ធិមនុស្សកំណត់ពីកម្រិតសមត្ថភាពរបស់ខ្លួន៦......................៥១
**V. សៀវភៅណែនាំទូទៅ ស្តីពីសន្តិសុខសុវត្ថិភាពសម្រាប់អ្នកការពារសិទ្ធិមនុស្ស............. ៥៣**
១. រដ្ឋនានា និងអង្គការថ្នាក់តំបន់ ..................................................................៥៤
២. ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)................................៥៤
៣. អង្គការសង្គមស៊ីវិលអន្តរជាតិ.....................................................................៥៥
**១. អ្នកការពារជួរមុខ ......................................................................៥៥**
**២. កិច្ចការពារជាអន្តរជាតិ .............................................................៥៥**
**៣. ការពារអ្នកការពារ ...................................................................៥៥**
**៤. អង្គការសង្គមស៊ីវិលកម្ពុជា .....................................................................៥៦**
១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR).............................................៥៦
២. អង្គការសមធម៌កម្ពុជា (EC) .........................................................៥៦
**VI. អង្គការនានាដែលជួយគាំទ្រដល់អ្នកការពារសិទ្ធិមនុស្ស.......................................... ៥៧**
**១. អង្គការសង្គមស៊ីវិលកម្ពុជា..........................................................................៥៨**
១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)..............................................៥៨
២. សមាគមអាដហុក ការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) ....៥៨
៣. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)..................៥៨
**២. អង្គការសង្គមស៊ីវិលអន្តរជាតិ .................................................................៥៩**
១. វេទិកាអាស៊ី សម្រាប់ការអភិវឌ្ឍន៍សិទ្ធិមនុស្ស (Forum-Asia) ...................៥៩
២. អ្នកការពារសិទ្ធិមនុស្សអន្តរជាតិ (Protection International) ................៥៩
៣. អ្នកការពារសិទ្ធិមនុស្សជួរមុខ (Front Line Defenders) .........................៥៩
៤. អង្គការសហព័ន្ធអន្តរជាតិ សម្រាប់សិទ្ធិមនុស្ស (FIDH)..............................៦០
៥. អង្គការ OMCT SOS-បណ្តាញអំពើទារុណកម្ម .........................................៦០
៦. អ្នករាយការណ៍ឥតព្រំដែន (Reporters without Borders)...................៦០
៣. យន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ...................................................៦១
១. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស .......................៦១
២. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា........................៦១
៣. យន្តការបណ្តឹងជាអន្តរជាតិ.................................................................៦១
**៤. ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា.............. ៦៣**
**៥. រដ្ឋនានា និងអង្គការថ្នាក់តំបន់.................................................................៦៤**
១. សហភាពអឺរ៉ុប..................................................................................៦៤
២. ប្រទេសហូឡង់ ...................................................................................៦៤
**ឧបសម្ព័ន្ធ** សេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើសកម្មភាពរបស់
សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋាន។.........៦៥

# I.

# សេចក្តីផ្តើម

# ១. គោលការណ៍ណែនាំនេះ ធ្វើឡើងសម្រាប់នរណា ?

## ១ ) បទប្បញ្ញត្តិទូទៅ

“ មនុស្សម្នាក់ៗ អាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ។ [...]” ”

(មាត្រា២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស)។

“ ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ”

(មាត្រា៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)។

“ ជនគ្រប់រូបមានសិទ្ធិដែលជាបុគ្គល និងចូលរួមសមាគមជាមួយអ្នកដទៃ ក្នុងការលើកកម្ពស់ និងការខំប្រឹងប្រែងការពារនិងធ្វើឲ្យសម្រេចបាននូវសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាននៅថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ ”

(មាត្រា១ នៃសេចក្តីប្រកាសស្តីពីសិទ្ធិនិងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងស្ថាប័ននានាក្នុងសង្គម ដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល (សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស)

“ **អ្នកការពារសិទ្ធិមនុស្ស** ”

គឺជាពាក្យសម្រាប់ពណ៌នាអំពីមនុស្សដែលជាបុគ្គលម្នាក់ៗ ឬរួមគ្នាជាមួយអ្នកដទៃ ធ្វើសកម្មភាពដើម្បីលើកកម្ពស់ ឬការពារសិទ្ធិមនុស្ស។ អ្នកការពារសិទ្ធិមនុស្ស កត់ត្រាជាឯកសារ និងអំពាវនាវឲ្យមានការយកចិត្តទុកដាក់ទៅលើការរំលោភ និងការបំពាននានា ដោយតួអង្គណាមួយដោយរាប់បញ្ចូលទាំង រដ្ឋាភិបាល ធុរកិច្ច បុគ្គល ក្រុម ឬ តួអង្គដែលមិនមែនជារដ្ឋ”(ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)) អនុលោមតាមកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ កម្ពុជាត្រូវតែជៀសវាងឲ្យខានតែបានពីការរំលោភ

សិទ្ធិអ្នកការពារសិទ្ធិមនុស្ស ដោយសារតែការងារសិទ្ធិមនុស្ស ដើម្បីការពារអ្នកការពារសិទ្ធិមនុស្សឲ្យរួចផុតពីការរំលោភបំពានពីសំណាក់ភាគីទីបីណាមួយ ព្រោះតែការងារសិទ្ធិមនុស្ស និងការលើកកម្ពស់ការយល់ដឹងពេញលេញពីសិទ្ធិអ្នកការពារសិទ្ធិមនុស្ស។

## ២. និយមន័យ អ្នកការពារសិទ្ធិមនុស្ស

- ការងាររបស់អ្នកការពារសិទ្ធិមនុស្សទាំងឡាយ មិនអាចកាត់ថ្លៃបានឡើយ ដើម្បីធ្វើឲ្យមានការយល់ជ្រួតជ្រាបពេញលេញអំពីការការពារ និងការលើកកម្ពស់សិទ្ធិមនុស្ស ដែលរួមមានការប្រមូល និងការផ្សព្វផ្សាយព័ត៌មាន ការតស៊ូមតិ និងការប្រមូលមតិយោបល់សាធារណៈ ការផ្តល់សិទ្ធិអំណាចក៏ដូចជា ផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្ស។ អ្នកការពារសិទ្ធិមនុស្ស ដើរតួនាទីយ៉ាងសំខាន់ ជំរុញឲ្យមានការចូលរួមក្នុងជីវភាពនយោបាយ និងជំរុញឲ្យមានអភិបាលកិច្ចល្អ និងមានតម្លាភាព។
- អ្នកការពារសិទ្ធិមនុស្សអាចជា ស្រ្តី បុរស កុមារា ឬ កុមារី ទោះមានសាវតាអ្វីក៏ដោយ។
- អ្នកការពារសិទ្ធិមនុស្សអាចមានជាអាទិ៍៖
    - អ្នកសារព័ត៌មាន រាប់ទាំងក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម
    - អ្នកសរសេរប្លុក
    - សកម្មជន មានដូចជា ស្រ្តី យុវជន សហគមន៍ ដីធ្លី ។ល។
    - សកម្មជននយោបាយ
    - សហជីព
    - សកម្មជនប្រឆាំងអំពើពុករលួយ
    - បុគ្គលិកអង្គការសង្គមស៊ីវិល
    - មេធាវី (អ្នកច្បាប់)
    - បុគ្គលិកសុខាភិបាល
    - គ្រូបង្រៀន
    - សិល្បករ
- អ្នកការពារសិទ្ធិមនុស្ស ត្រូវបានកំណត់តាមរយៈអ្វីដែលពួកគេធ្វើ គាំទ្រដល់សិទ្ធិមនុស្ស
- អ្នកការពារសិទ្ធិមនុស្ស លើកកម្ពស់រាល់បញ្ហាសិទ្ធិមនុស្ស មានជាអាទិ៍ សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។
- អ្នកការពារសិទ្ធិមនុស្ស ធ្វើការងារតំណាងឲ្យបុគ្គល ឬក្រុមក៏បាន។
- ក្នុងគោលការណ៍ណែនាំនេះ អង្គការសង្គមស៊ីវិល សំដៅដល់អ្នកការពារសិទ្ធិមនុស្ស រួមគ្នាធ្វើការដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។
- សង្គមស៊ីវិល អាចជា សមាគមផ្លូវការ អង្គការមិនមែនរដ្ឋាភិបាល ឬសហជីព ប៉ុន្តែក៏អាចជាក្រុមសហគមន៍មូលដ្ឋានក្រៅផ្លូវការផងដែរ។

# ២. តើគោលការណ៍ណែនាំនេះ ធ្វើឡើងដើម្បីអ្វី ?

ផ្តល់ការណែនាំជាក់ស្តែងដល់អ្នកការពារសិទ្ធិមនុស្ស ដើម្បីពង្រឹងសន្តិសុខសុវត្ថិភាព និងកិច្ចការពារដល់ពួកគេ។

ជួយអ្នកការពារសិទ្ធិមនុស្សឲ្យចេះទទួលខុសត្រូវលើដំណើរការទាំងមូល ការពារសន្តិសុខសុវត្ថិភាពដោយ ខ្លួនឯង។

ជួយអ្នកការពារសិទ្ធិមនុស្សឲ្យចេះបង្កើតនីតិវិធីផ្សេងៗ ដើម្បីពង្រឹងសន្តិសុខសុវត្ថិភាពដោយខ្លួនឯង។

ជួយអ្នកការពារសិទ្ធិមនុស្សឲ្យចេះវាយតម្លៃហានិភ័យផ្សេងៗដែលពួកគេប្រឈម។

ជួយអ្នកការពារសិទ្ធិមនុស្សឲ្យចេះកំណត់ពីការគំរាមកំហែង និងភាពងាយរងគ្រោះនៅក្នុងបរិយាកាសការងាររបស់ខ្លួន។

ជួយអ្នកការពារសិទ្ធិមនុស្សឲ្យចេះកំណត់ពីកម្រិតសមត្ថភាពដែលមាន ឬដែលអាចកសាងបន្ថែម

## បម្រាម

អ្នកការពារសិទ្ធិមនុស្សម្នាក់ៗ ត្រូវប្រើប្រាស់សៀវភៅណែនាំនេះ ឲ្យស្របទៅតាមតម្រូវការការងារជាក់លាក់របស់ខ្លួន

ការណែនាំនេះ មិនអនុវត្តចំពោះគ្រប់អ្នកការពារសិទ្ធិមនុស្ស ដែលកំពុងរងការគំរាមកំហែងឡើយ

ត្រូវចងចាំថា គ្មានសៀវភៅណាមួយ ណែនាំប្រាប់អ្នកពីរបៀបធ្វើឲ្យអ្នកមានសន្តិសុខសុវត្ថិភាពទាំងស្រុងនោះឡើយ

## ៣. ពាក្យគន្លឹះ

**សន្តិសុខសុវត្ថិភាព**
ចាកផុតពីហានិភ័យ គ្រោះថ្នាក់ ឬ ការគំរាមកំហែង

**ការការពារ**
ចាត់វិធានការ ដើម្បីពង្រឹងសន្តិសុខសុវត្ថិភាព

**ហានិភ័យ**
ប្រឈមនឹងគ្រោះថ្នាក់ និងអន្តរាយ

**ការគំរាមកំហែង**
ប្រឈមនឹងបុគ្គល ឬវត្ថុអ្វីមួយដែលបង្កឲ្យមានការខូចខាត

**ភាពងាយរងគ្រោះ**
ប្រឈមនឹងលទ្ធភាពដែលអាចរងការវាយប្រហារ

**កម្រិតសមត្ថភាព**
ចំណុចខ្លាំង និងធនធានដែលជួយពង្រឹងដល់សន្តិសុខសុវត្ថិភាព

**ឧបទ្ទវហេតុសន្តិសុខ**
ព្រឹត្តិការណ៍ដែលអាចចង្អុលបង្ហាញ ឬដែលនាំទៅដល់ការគំរាមកំហែងផ្សេងៗ

# ៤. តម្រុយដែលមានសារៈប្រយោជន៍ខ្លះ។

ត្រូវតែប្រុងប្រយ័ត្នជាប់ជានិច្ច

ត្រូវរក្សាការសម្ងាត់ ដូចជា ផែនការការធ្វើសកម្មភាពទីតាំង និងការជួបប្រជុំជាមួយមនុស្សម្នាផ្សេងៗ

ត្រូវផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមក សម្រាប់តែបុគ្គលដែលអាចទុកចិត្តបាន ដូចជាក្រុមគ្រួសារ ឬ សហការី ជាដើម។

ត្រូវមានសុភវិនិច្ឆ័យ ផ្អែកលើព័ត៌មានដែលមានគុណភាព និងការវិភាគដ៏ត្រឹមត្រូវ។

ត្រូវវិភាគស្ថានការណ៍ឡើងវិញឲ្យបានទៀងទាត់ ដើម្បីកែតម្រូវទៅលើសកម្មភាព និងផែនការនានា។

ត្រូវវាយតម្លៃហានិភ័យ ក្នុងករណីនីមួយៗ និងនៅគ្រប់ដំណាក់កាល។

ត្រូវជឿជាក់លើខ្លួនឯង ពីព្រោះមានតែខ្លួនឯងទេ ដែលយល់ដឹងច្បាស់ជាងអ្នកដទៃ អំពីស្ថានភាពជុំវិញខ្លួន។

ត្រូវរក្សាការទទួលខុសត្រូវចំពោះសន្តិសុខសុវត្ថិភាពផ្ទាល់ខ្លួន ជៀសវាងការចេះតែពឹងផ្អែកទៅលើអ្នកដទៃ។

មិនត្រូវយកនរណាឲ្យប្រឈមនឹងបញ្ហាទេ ប្រសិនបើអ្នកមិនអាចរក្សាសន្តិសុខសុវត្ថិភាពឲ្យពួកគេបាននោះ។

មិនត្រូវផ្តល់ក្តីសង្ឃឹម ប្រសិនបើអ្នកមិនអាចធ្វើបានទេនោះ។

# II.

# ហានិភ័យដែលអ្នកការពារសិទ្ធិមនុស្សប្រឈម

# ១. ការចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើអ្នកការពារសិទ្ធិមនុស្ស និងការបំភិតភ័យតាមផ្លូវច្បាប់ និងតាមផ្លូវរដ្ឋបាល

## ១. បទប្បញ្ញត្តិ

“ជនគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង។”

(មាត្រា៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស)។

“គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន តាមអំពើចិត្តឡើយ”

(មាត្រា៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស)។

“ជនគ្រប់រូប មានសិទ្ធិមានសេរីភាពនិងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។”

(មាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ)

“ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។”

(មាត្រា៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)

“ពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន។”

(មាត្រា៣២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)

“ច្បាប់ការពារមិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ”

(មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)

“ការចោទប្រកាន់ការចាប់ខ្លួនការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។”

(មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)

## ២. ផលប៉ះពាល់នៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើអ្នកការពារសិទ្ធិមនុស្ស

ការចាប់ខ្លួនដោយមាន ឬដោយគ្មាន ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងការគំរាមចាប់ខ្លួន ដែលគេប្រើប្រាស់ជាវិធីបំភិតបំភ័យដល់អ្នកការពារសិទ្ធិមនុស្ស និងរារាំងកុំឲ្យមានការតវ៉ាសង្គម។

ការចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើអ្នកការពារសិទ្ធិមនុស្ស គឺជាការបង្អាក់ដល់កិច្ចខិតខំប្រឹងប្រែងក្នុងការការពារសិទ្ធិមនុស្ស ដោយសារតែពួកគេងាកមកប្រើប្រាស់ពេលវេលាធនធាន និងថាមពលរបស់ខ្លួនយកមកការពារខ្លួនឯងទៅវិញ។

### ◗ ផលប៉ះពាល់ផ្លូវចិត្ត

ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ធ្វើឲ្យប៉ះពាល់ផ្លូវចិត្តអ្នកការពារសិទ្ធិមនុស្ស និងមានផលប៉ះពាល់អវិជ្ជមានទៅលើការងាររបស់ពួកគេ ហើយបង្កើតឲ្យមានស្ថានភាពភ័យខ្លាច ភាពមិនប្រាកដប្រជា ភាពមិនអាចការពារខ្លួនបាន ភាពងាយរងគ្រោះ និងភាពឯកោ ដែលជាប្រភពប៉ះពាល់ផ្លូវចិត្ត។

ភាពតានតឹងក្នុងអារម្មណ៍ គឺជាប្រតិកម្ម ដែលដាក់សម្ពាធ ឬក៏ទាមទារអ្វីមួយពីមនុស្ស។ បញ្ហានេះវាធ្វើឲ្យប៉ះពាល់ដល់សុខភាពផ្លូវចិត្ត (ធ្វើឲ្យមានអារម្មណ៍ ដូចជា ឆាប់ខឹង អន្ទះសារក្នុងចិត្ត បាក់ទឹកចិត្ត) ទៅលើអាកប្បកិរិយា (ភាពធុញថប់ ហូបច្រើន ឬការទទួលគ្រឿងស្រវឹងច្រើន គេងមិនលក់) និងទៅលើរាងកាយរបស់ពួកគេ (ដូចជា ក្តៅរងារ ឬឆ្លងជំងឺផ្សេងៗទៀត ឆាប់ញ័របេះដូង ចប់ដង្ហើម ឈឺដើមទ្រូង ឈឺក្បាល ។ល។)។

ការបំពារបំពាន ការបំភិតបំភ័យ និងការគំរាមកំហែង ព្រមទាំងការងារស្មុគស្មាញរបស់ខ្លួន បង្កើតជាប្រភពមួយដ៏សំខាន់នៃភាពតានតឹងក្នុងអារម្មណ៍អ្នកការពារសិទ្ធិមនុស្ស ដែលអាចនាំឲ្យគេឈប់ធ្វើសកម្មភាពផ្សេងៗ ដោយសារតែបញ្ហាអារម្មណ៍។

ការធ្វើការនៅក្នុងការិយាល័យតែឯកឯង អាចនាំឲ្យមានផលប៉ះពាល់អវិជ្ជមានដល់ខ្លួនឯង នាំឲ្យមានភាពធុញថប់ក្នុងអារម្មណ៍របស់អ្នកការពារសិទ្ធិមនុស្សដទៃផ្សេងទៀត និងអាចឈានដល់ការបាក់ទឹកចិត្តធ្ងន់ធ្ងរ។

### ◗ ផលប៉ះពាល់លើជីវិតរស់នៅរបស់គ្រួសារអ្នកការពារសិទ្ធិមនុស្ស

ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ អាចនាំឲ្យមានផលប៉ះពាល់ដល់ជីវិតរស់នៅរបស់គ្រួសារអ្នកការពារសិទ្ធិមនុស្ស ដូចជាការបែកបាក់គ្រួសារជាដើម។ ការរើសអើងភ្ជាប់ទៅនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គល និងអាចជះឥទ្ធិពលអាក្រក់ទៅលើទំនាក់ទំនងសង្គម និងសមាជិកគ្រួសារឯទៀត។ ចំណែកឯកូនៗរបស់អ្នកការពារសិទ្ធិមនុស្សវិញ អាចនាំឲ្យពួកគេមានភាពអន្ទះសារក្នុងអារម្មណ៍ និងមានបញ្ហាផ្សេងៗនៅសាលារៀន។

## ផលប៉ះពាល់លើការងាររបស់អ្នកការពារសិទ្ធិមនុស្ស

### សកម្មជនៈ សហគមន៍ ដីធ្លី បរិស្ថាន

អ្នកការពារសិទ្ធិមនុស្សដែលធ្វើការងារពាក់ព័ន្ធនឹងបញ្ហាដីធ្លីការការពារ និងការអភិរក្សធនធានធម្មជាតិ អាចប្រឈមនឹងការលំបាកជាក់លាក់មួយចំនួន នៅក្នុងការបំពេញការងារ និងសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន។ សកម្មជនដែលធ្វើការជិតស្និទ្ធជាមួយក្រុមជនជាតិដើមភាគតិចផ្សេងៗ ក៏ជួបប្រទះនឹងបញ្ហារឹតត្បិតស្រដៀងគ្នានេះដែរ។

ជារឿយៗ ពួកគេតែងទទួលរងនូវសម្ពាធ ដោយសារតែពួកគេៈ

- ធ្វើការនៅតំបន់ដាច់ស្រយាល។
- ទទួលបានព័ត៌មានពីបណ្ដាញផ្សព្វផ្សាយ និងសហគមន៍អន្តរជាតិ ក្នុងកម្រិតតិចតួចបំផុត។
- ពិបាករកអ្នកច្បាប់ ឬការផ្ដល់ប្រឹក្សាយោបល់ពីច្បាប់ និងពីស្ថាប័នផ្សេងៗនៃប្រព័ន្ធយុត្តិធម៌។
- ខ្វះមធ្យោបាយផ្នែកហិរញ្ញវត្ថុ។

### អ្នកសារព័ត៌មានឯករាជ្យ

សន្តិសុខសុវត្ថិភាពរបស់អ្នកសារព័ត៌មានឯករាជ្យ មានសារៈសំខាន់ណាស់ ដោយសារតែពួកគេអាចទទួលរងការយាយីរំខាន និងការគំរាមកំហែង កើតចេញពីការងាររបស់ពួកគេ។ អាជ្ញាធរ នគរបាល និងក្រុមហ៊ុនឯកជននានា ក៏អាចជាគោលដៅវាយប្រហារទៅលើសកម្មជនប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលអាចឈានដល់ការចាប់ខ្លួន។ ជួនកាល អ្នកសារព័ត៌មានអាចនឹងស្វែងរក សុំសិទ្ធិជ្រកកោន ដោយសារតែពួកគាត់ទទួលរងការយាយីរំខាន ឬការគំរាមកំហែង។

### សកម្មជនសហជីព

កម្មករអាចត្រូវបានគេដាក់ទោសទណ្ឌ ដោយសារតែការចូលរួមក្នុងការងារសហជីព ឬចូលរួមការតវ៉ា។មេដឹកនាំសហជីពក៏អាចជាគោលដៅនៃការគំរាមកំហែង និងការយាយីរំខានជាប្រចាំ។ សកម្មជនតែងតែប្រឈមនឹងការលំបាកផ្សេងៗ ក្នុងការការពារខ្លួនគេ ដោយសារតែពួកគេខ្វះលទ្ធភាពទទួលបានការការពារផ្នែកច្បាប់ ក៏ដូចជា ទំនាក់ទំនង ជាមួយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអន្តរជាតិនានា ហើយជារឿយៗ មិនមានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់។

### ស្ត្រីដែលជាអ្នកការពារសិទ្ធិមនុស្ស

តាមធម្មតា ស្ត្រីអ្នកការពារសិទ្ធិមនុស្សប្រឈមនឹងបញ្ហាដូចគ្នានឹងអ្នកការពារសិទ្ធិមនុស្សទូទៅផងដែរ។ ក៏ប៉ុន្តែ ស្ត្រីអ្នកការពារសិទ្ធិដែលទទួលរងនូវសម្ពាធដោយឡែកផ្សេងទៀតខុសពីបុរស ហើយជារឿយៗ អ្នកការពារសិទ្ធិជាស្ត្រី ប្រឈមនឹងការគំរាមកំហែង និងអំពើហិង្សាផ្លូវភេទ។

ស្ត្រីការពារសិទ្ធិមនុស្សអាចទទួលរងដូចជា៖

- ការយាយីផ្លូវភេទ
- ការជេរប្រមាថ ដោយប្រើភាសា ឬកាយវិការផ្សេងៗ។
- ការយល់ខុសពីសហការីដែលជាបុរស បដិសេធមិនទទួលស្គាល់ពីការចូលរួមរបស់ស្ត្រី។
- អំពើហិង្សាក្នុងគ្រួសារ។
- សម្ពាធពីគ្រួសារ។

- សកម្មជនអង្គការសង្គមស៊ីវិល

សកម្មជនអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការក្នុងវិស័យការពារ និងលើកកម្ពស់សិទ្ធិមនុស្ស អាចប្រឈមនឹងការគំរាមកំហែង និងការវាយប្រហារ ពីសំណាក់អាជ្ញាធរ នគរបាល និងឬក្រុមហ៊ុនដែលមានអំណាច និងផលប្រយោជន៍សេដ្ឋកិច្ច។

ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ លើអ្នកការពារសិទ្ធិមនុស្ស នាំឲ្យមានផលប៉ះពាល់អវិជ្ជមានលើការងារអង្គការ ធ្វើឲ្យអង្គការសង្គមស៊ីវិលមួយចំនួន ត្រូវបញ្ឈប់សកម្មភាពការពារសិទ្ធិមនុស្សរបស់ខ្លួនផងដែរ។

ផលប៉ះពាល់លើសហការីអ្នកការពារសិទ្ធិមនុស្ស ក៏អាចជាបញ្ហាសំខាន់ផងដែរ ព្រោះអ្នកគេអាចសម្រេចចិត្តឈប់ពីការងារ ដោយសារតែគេខ្លាចក្លាយជាគោលដៅនៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌ។ នេះក៏ជាការបញ្ជូនសារបង្អាក់ទឹកចិត្ត ដល់មនុស្សគ្រប់រូប ដែលសកម្មក្នុងការការពារសិទ្ធិមនុស្ស។

## ៣. ការគំរាមកំហែង ដែលអ្នកការពារសិទ្ធមនុស្សប្រឈម

- អាចត្រូវគេវាយដំលើរូបរាងកាយ
- អាចត្រូវបានចាប់ខ្លួន និងនាំខ្លួន តាមប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។
- អាចត្រូវប្រឈមនឹងបទចោទប្រកាន់បែបប្រឌិត និងអាចជាប់ពន្ធនាគារ។
- អាចត្រូវបានចោទប្រកាន់ពី “បទបង្កចកិត្តិយសជាតិ” ឬក៏ “ប្រឆាំងរដ្ឋ” “ធ្វើជាភ្នាក់ងារឲ្យបរទេស” ឬ “សមាជិកគណបក្សប្រឆាំង”។
- អាចត្រូវបានបំភិតបំភ័យ ដោយក្រុមដែលមានអំណាចខាងសេដ្ឋកិច្ច។
- អាចត្រូវបានបំភិតបំភ័យ តាមរយៈការគំរាមកំហែងលើសមាជិកគ្រួសារ។
- អាចត្រូវគេរារាំងមិនឲ្យធ្វើសកម្មភាពផ្សេងៗ ជាពិសេស នៅពេលដែលពួកគេចង់យកករណីរបស់ខ្លួន ទៅស្វែងរកយុត្តិធម៌។
- អាចត្រូវគេរារាំងមិនឲ្យមានការរៀបចំការជួបប្រជុំ សិក្ខាសាលា និងការបណ្តុះបណ្តាលផ្សេងៗ។

# ២. ការដាក់កំហិតលើសេរីភាពសម្ដែងមតិ សេរីភាពខាងសមាគម និងសេរីភាពក្នុងការជួបប្រជុំ

## ១) សេរីភាពសម្ដែងមតិ

- បទប្បញ្ញត្តិ

"មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់។ សិទ្ធិនេះ រាប់ទាំងសេរីភាពក្នុងការប្រកាន់យកមតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែន។"

(មាត្រា១៩ នៃសេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស)

"មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មានទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយគ្មានព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្ដី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្ដី តាមការជ្រើសរើសរបស់ខ្លួន"

(មាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)

"ច្បាប់ស្ដីពីរបបសារព័ត៌មានកម្ពុជា ឆ្នាំ១៩៩៥ ធានាលើ "សេរីភាពសារព័ត៌មាន" និង "សេរីភាពខាងការបោះពុម្ពផ្សាយ" (មាត្រា១)។ ច្បាប់នេះក៏ធានាដែរថា "ការបោះពុម្ពផ្សាយនូវព័ត៌មានផ្លូវការ មិនអាចត្រូវផ្ដន្ទាទោសបានឡើយ ប្រសិនបើជាការផ្សាយនោះមានលក្ខណៈសមស្របតាមសភាពពិតពេញលេញ ឬសេចក្ដីសង្ខេបត្រឹមត្រូវតាមរឿងពិត"

(មាត្រា៤)។

- ការដាក់កំហិតដែលមានចរិតលក្ខណៈមិនជាក់លាក់ទៅលើសេរីភាពសម្ដែងមតិ
  - ជាគោលដៅធ្វើឲ្យអាជ្ញាធរអាចបង្ខំបិទស្ថានីយទូរទស្សន៍ វិទ្យុ ឬបណ្ដាញសារព័ត៌មានផ្សេងៗ
  - ធ្វើឲ្យអ្នកសារព័ត៌មានឯករាជ្យ និងសកម្មជនប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន មិនអាចមានលទ្ធភាពរាយការណ៍ព័ត៌មានដែលមានចរិតលក្ខណៈរិះគន់ទៅលើរាជរដ្ឋាភិបាល។ ពួកគេអាចទទួលរងនូវអំពើហិង្សា ឬការយាយីរំខានតាមផ្លូវរដ្ឋបាល និងផ្លូវច្បាប់ ប្រសិនបើពួកគេនៅតែព្យាយាមរាយការណ៍អំពីបញ្ហានយោបាយ ឬបញ្ហាសេដ្ឋកិច្ចផ្សេងៗ។

- ការបំភិតបំភ័យ នាំឲ្យមានការភ័យខ្លាច និងបង្កើតឲ្យមានវប្បធម៌រឹតត្បឹតញញើតញញើម។

## ២. សេរីភាពនៃការជួបប្រជុំ

- **បទប្បញ្ញត្តិ**

**“ មនុស្សគ្រប់រូបមានសិទ្ធិសេរីភាព ក្នុងការជួបប្រជុំ ឬការបង្កើតសមាគមដោយសន្តិវិធី ”**

(មាត្រា ២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស)

**“ សិទ្ធិជួបប្រជុំដោយសន្តិវិធីត្រូវតែទទួលស្គាល់។ ការប្រើប្រាស់សិទ្ធិនេះ អាចមានការរឹតត្បឹត ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ [...]” ”**

(មាត្រា២១ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ)

**“ ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ជនគ្រប់រូបមានសិទ្ធិដោយបុគ្គល និងដោយរួមជាមួយអ្នកដទៃ នៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ក្នុងការជួបឬប្រជុំដោយសន្តិវិធី [...]” ”**

(មាត្រា៥ នៃសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស)

**“ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ ”**

(មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)

**“ សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់។ ”**

(មាត្រា៣៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)

**“ ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ”**

(មាត្រា៤១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)

មាត្រា២ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងថាច្បាប់នេះ មានគោលបំណងធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ តាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី (មាត្រា២)។

យោងតាមការជូនដំណឹងរបស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ “សមាគម អង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ ក៏ដូចជាសហគមន៍មូលដ្ឋាន មានសិទ្ធិសេរីភាពពេញលេញក្នុងការធ្វើសកម្មភាព ក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ព្រមទាំងលក្ខន្តិកៈរបស់ខ្លួនដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនតម្រូវឲ្យមានការជូនដំណឹងមុន ០៣ ថ្ងៃ មុនពេលចាប់ផ្តើមធ្វើសកម្មភាព ដូចដែលបានតម្រូវពីមុនទៀយ”។

- **ការដាក់កំហិតដែលមានចរិតលក្ខណៈមិនជាក់លាក់លើសេរីភាពជួបប្រជុំ**
  - ការជួបប្រជុំ ឬសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល អាចមានការលំបាកនឹងធ្វើទៅបាន ប្រសិនបើតម្រូវឲ្យមានការជូនដំណឹង និងតម្រូវឲ្យមានការអនុម័តយល់ព្រម ប្រសិនបើ អាជ្ញាធរមូលដ្ឋានមិនយកច្បាប់នេះមកអនុវត្តជាគោលទេនោះ នោះការអនុវត្តនឹងមិនស៊ីសង្វាក់គ្នាឡើយ។
  - ការស្នើសុំរៀបចំកិច្ចប្រជុំ អាចនឹងត្រូវបានបដិសេធ ឬជាកម្មវត្ថុនៃការបដិសេធដោយគ្មានច្បាប់ធ្វើជាមូលដ្ឋាន។

## ៣) សេរីភាពសមាគម

- **បទប្បញ្ញត្តិ**

**“ មនុស្សគ្រប់រូបមានសិទ្ធិជាបុគ្គល និងដោយរួមជាសមាគមជាមួយអ្នកដទៃ ចូលរួមក្នុងសកម្មភាពដោយសន្តិវិធី ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ”**

(មាត្រា១២ នៃសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស)

**“ មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការជួបប្រជុំ ឬការបង្កើតសមាគមដោយសន្តិវិធី ”**

(មាត្រា ២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស)

**“ ជនគ្រប់រូប មានសិទ្ធិសេរីភាពចូលរួមជាសមាគមជាមួយអ្នកដទៃ រាប់បញ្ចូលទាំងសិទ្ធិបង្កើត សហជីព និងសិទ្ធិចូលរួមជាសមាជិកសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។ ”**

(មាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)

**“ ក្នុងរដ្ឋដែលមានក្រុមជនជាតិភាគតិចខាងជាតិពន្ធ សាសនា ឬភាសា ជនដែលជាសមាជិកជនភាគតិចទាំងនេះ ដោយរួមនឹងសមាជិកដទៃទៀតនៃក្រុមរបស់ខ្លួន មិនត្រូវទទួលរងការរារាំង សិទ្ធិអាស្រ័យផលតាមបែបវប្បធម៌របស់ពួកគេ សិទ្ធិកាន់ និងប្រតិបត្តិសាសនារបស់ពួកគេ តាមទម្លាប់ពួកគេ ឬសិទ្ធិប្រើប្រាស់ភាសារបស់ពួកគេឡើយ។ ”**

(មាត្រា២៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)

**“ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ជនគ្រប់រូបមានសិទ្ធិជាឯកជន និងចូលរួមជាមួយអ្នកដទៃ នៅថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ” ... “ក្នុងការបង្កើត ចូលជាសមាជិក និងចូលរួមនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល សមាគម ឬក្រុម ដើម្បីទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការអន្តររដ្ឋាភិបាលនានា**

(មាត្រា៥ នៃសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស)

**ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវបានកំណត់ក្នុងច្បាប់។” ហើយ “ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។**

(មាត្រា៤២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)

**ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីព។**

(មាត្រា៣៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា)

### ការដាក់កំហិតដែលមានចរិតលក្ខណៈមិនជាក់លាក់លើសេរីភាពសមាគម

- ការចុះបញ្ជី ឬការចុះបញ្ជីឡើងវិញរបស់អង្គការនានា
  - ការដាក់លក្ខខណ្ឌតម្រូវឲ្យអង្គការសង្គមស៊ីវិលចាំបាច់ត្រូវតែចុះបញ្ជី ដើម្បីឲ្យពួកគេអាចអនុវត្តសកម្មភាពរបស់ខ្លួនបាននោះ គឺជាការដាក់កំហិតទៅលើសេរីភាពសមាគម។
  - សិទ្ធិផ្អាកដំណើរការ ឬលុបចេញពីបញ្ជីអង្គការសង្គមស៊ីវិល ដោយគ្រាន់តែគេពុំបានប្រតិបត្តិតាមលក្ខន្តិកៈអង្គការរបស់ខ្លួន នោះក៏ជាការដាក់កំហិតទៅលើសេរីភាពសមាគមផងដែរ បើទោះជាគ្មានច្បាប់ចែងថាជាបទល្មើស។
- ការដាក់ការត្រួតពិនិត្យផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ

លំហសង្គមស៊ីវិល អាចនឹងរួមតូចទៅៗ ដោយសារតែមានការដាក់ការត្រួតពិនិត្យផ្នែករដ្ឋបាល និងហិរញ្ញវត្ថុលើអង្គការសង្គមស៊ីវិល មានជាអាទិ៍ ដូចជា៖

  - ការចុះបញ្ជីការ៖ អង្គការសង្គមស៊ីវិលអាចត្រូវបានគេទាមទារឲ្យដាក់របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ពាក់ព័ន្ធកិច្ចព្រមព្រៀងមូលនិធិទាំងអស់ជាមួយនឹងម្ចាស់ជំនួយ។ ប្រសិន បើចាំបាច់ អាជ្ញាធរអាចស្នើសុំអង្គការ ផ្តល់ឯកសារចម្លងនៃរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនបាន។ ពួកគេមានរចនាសម្ព័ន្ធជាក់លាក់អំពីការត្រួតពិនិត្យ និងការធ្វើសវនកម្មផ្សេងៗជាស្រេចទៅហើយ។

- ការនេះ ធ្វើឲ្យអាជ្ញាធរអនុវត្តស្តង់ដារខុសគ្នាទៅតាមសកម្មភាពរបស់អង្គការសង្គមស៊ីវិលនីមួយៗ។

▶ ការដាក់ការតាមឃ្លាំមើលដល់ការិយាល័យ

មន្ត្រីនគរបាល អាចឃាយឃីរំខានអ្នកការពារសិទ្ធិមនុស្ស ដោយដាក់ការតាមដាន និងឃ្លាំមើលជាប្រចាំដល់ការិយាល័យពួកគេ និងដោយសួរនាំពីចំនួនបុគ្គលិក ឧទា. ដូចជា សួរកឈ្មោះ ឬ លេខទូរស័ព្ទ។ល។ ឬក៏អាចសួរនាំរកឯកសារចុះបញ្ជី និងសកម្មភាពផ្សេងៗ។ មន្ត្រីនគរបាល អាចនឹងថតរូបទីតាំងការិយាល័យនោះផងដែរ។

▶ ការដាក់ការតាមឃ្លាំមើលពីសកម្មភាពការងារ

មន្ត្រីនគរបាល និងឬអាជ្ញាធរ អាចរំខានដល់ការជួបប្រជុំ ដែលអ្នកការពារសិទ្ធិមនុស្សរៀបចំធ្វើ ដូចជា៖

- ការថតយករូបភាព ឬថតវីដេអូផ្សេងៗ
- សួរពីអត្តសញ្ញាណ ឬឯកសារផ្សេងៗរបស់អ្នកចូលរួម
- តាមជជីកសួរនាំអ្នកចូលរួមពីខ្លឹមសារនៃបទបង្ហាញផ្សេងៗ
- រារាំងអ្នកចូលរួមមិនឲ្យទៅចូលរួមប្រជុំបាន។

▶ ការដាក់ការតាមឃ្លាំមើលទៅលើបុគ្គលម្នាក់ៗ

- អាចមានគេលួចស្តាប់ការសន្ទនាតាមទូរស័ព្ទរបស់អ្នកការពារសិទ្ធិមនុស្ស ឬលួចមើលអ៊ីមែលគាត់ និងតាមឃ្លាំមើលថាតើគាត់ទៅទីណាកន្លែងណា ហើយគាត់ជួបជាមួយអ្នកណាខ្លះ។
- ការដាក់ការតាមឃ្លាំមើលនេះ គឺសំដៅដល់ការប្រមូលព័ត៌មាន ការបំភិតបំភ័យ ឬ ការត្រៀមចាប់ខ្លួន ឬ ការវាយប្រហារទៅលើអ្នកការពារសិទ្ធិមនុស្សណាម្នាក់។
- អ្នកការពារសិទ្ធិមនុស្សអាចត្រូវបានគេតាមដានជារៀងរាល់ថ្ងៃ ឬនៅក្នុងឱកាសជាក់លាក់ណាមួយ ឧទា. ដូចជា នៅក្នុងអំឡុងពេលបោះឆ្នោត ការជំនុំជម្រះនៅតុលាការ ។ល។ មន្ត្រីនគរបាល អាជ្ញាធរមូលដ្ឋាន ឬកងសន្តិសុខឯកជន ក៏អាចជាអ្នកទទួលខុសត្រូវក្នុងការតាមឃ្លាំមើលនេះផងដែរ។
- អ្នកជិតខាងនៃអ្នកការពារសិទ្ធិមនុស្ស ក៏អាចធ្វើជាអ្នកតាមឃ្លាំមើលការរស់នៅនិងការងាររបស់អ្នកការពារសិទ្ធិមនុស្ស ហើយរាយការណ៍ទៅអាជ្ញាធរផងដែរ។
- អ្នកការពារសិទ្ធិមនុស្សអាចត្រូវបានរារាំងមិនឲ្យធ្វើដំណើរទៅចូលរួមនៅក្នុងព្រឹត្តិការណ៍ណាមួយ ឧទា. ដូចជា ការចូលរួមប្រជុំ ឬការដាក់បណ្តឹង ឬការដាក់ញត្តិអ្វីមួយ។
- ការរឹតត្បិតលើការធ្វើដំណើរ អាចត្រូវបានដាក់កំហិតលើអ្នកការពារសិទ្ធិមនុស្សដែលទៅចូលរួមក្នុងកិច្ចប្រជុំ និងវេទិកាអន្តរជាតិនានា ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។

# III.

# ដំណាក់កាលក្នុងការពង្រឹងសន្តិសុខសុវត្ថិភាពអ្នកការពារសិទ្ធិមនុស្ស

# បម្រាម

មូលដ្ឋានគ្រឹះនៃការងារអ្នកការពារ
សិទ្ធិមនុស្ស ផ្អែកលើសន្តិសុខសុវត្ថិភាព
បើគ្មានសន្តិសុខសុវត្ថិភាពទេនោះ
ការងារសិទ្ធិមនុស្សក៏មិនមានដែរ

# តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីពង្រឹងសន្តិសុខសុវត្ថិភាពរបស់អ្នកការពារសិទ្ធិមនុស្ស

១ វិភាគទៅលើបរិស្ថានរស់នៅ និងបរិស្ថានការងារ

២ វាយតម្លៃហានិភ័យផ្សេងៗ

៣ វាយតម្លៃការគំរាមកំហែង និងវិភាគពីឧបទ្ទវហេតុសន្តិសុខសុវត្ថិភាពនានា

៤ វិភាគ និងពង្រឹងសមត្ថភាព

៥ រៀបចំធ្វើផែនការសន្តិសុខសុវត្ថិភាព

៦ អនុវត្ត និងពិនិត្យឡើងវិញទៅលើផែនការសន្តិសុខសុវត្ថិភាព

# ១. វិភាគលើបរិស្ថានរស់នៅ និងបរិស្ថានការងាររបស់អ្នក ការពារសិទ្ធិមនុស្ស

## តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីបានយល់ដឹងច្រើនថែមទៀត ជុំវិញបរិស្ថានរស់នៅ និងបរិស្ថានការងារ

សិក្សាពីផ្លូវផ្សេងៗជុំវិញលំនៅដ្ឋាន និងនៅជិតកន្លែងធ្វើការៈ ត្រូវដឹងថាមានអ្នកណារស់នៅទីនោះខ្លះ។

រក្សាទំនាក់ទំនងស្និទ្ធស្នាលជាមួយអ្នកជិតខាង ម្ចាស់ហាង អ្នកថែទាំ ជាពិសេសអ្នករស់នៅជិតខាង។

វិភាគថាតើអ្នកណាអាចជាការគំរាមកំហែងនៅក្នុងតំបន់ជិតខាងអ្នក។

ត្រូវធ្វើឲ្យប្រាកដថា កុមារស្ថិតក្នុងការគ្រប់គ្រងរបស់អ្នក ដោយសារតែ កុមារអាចនឹងងាយស្រួលផ្តល់ព័ត៌មានដល់ជនចម្លែក។

ត្រូវធានាថារាល់សមាជិកគ្រួសារទាំងអស់មានព័ត៌មានដូចគ្នា និងមានអាកប្បកិរិយាដូចគ្នា។



# ២. ការវាយតម្លៃពីហានិភ័យ

## តើនឹងត្រូវធ្វើដូចម្តេចខ្លះ

ត្រូវកំណត់រកឲ្យឃើញហានិភ័យផ្សេងៗ

ត្រូវព្យាយាមកំណត់រកឲ្យឃើញប្រភពនៃហានិភ័យ

## សំណួរដែលត្រូវសួរចំពោះហានិភ័យនីមួយៗដែលបានកំណត់

### ១. តើហានិភ័យនោះ អាចនឹងកើតឡើងក្នុងកម្រិតណា

ហានិភ័យនោះ វាអាស្រ័យទៅលើប្រវត្តិ និងសកម្មភាពដែលបានប្រព្រឹត្តទៅលើអ្នកការពារសិទ្ធិមនុស្ស។

ត្រូវដាក់ចំណាត់ថ្នាក់ កម្រិតហានិភ័យនីមួយៗ។ ឧទា. កម្រិតនៃហានិភ័យ អាចដាក់តាមលំដាប់ថ្នាក់ ដូចខាងក្រោមនេះ ៖

- កម្រិតទាបបំផុត
- កម្រិតទាប
- កម្រិតមធ្យម
- កម្រិតខ្ពស់
- កម្រិតខ្ពស់បំផុត

### ២. ប្រសិនបើមានហានិភ័យ តើនឹងមានផលប៉ះពាល់អ្វីខ្លះទៅលើបុគ្គលនោះ ?

វាយតម្លៃពីផលប៉ះពាល់ គួរតែពិចារណាទៅលើការខូចខាតផ្សេងៗ ដែលអាចកើតមានចំពោះបុគ្គលនោះ និងអង្គការរបស់គាត់។

ត្រូវចងចាំថា អ្នកការពារសិទ្ធិមនុស្ស ពេលខ្លះស្ថិតក្នុងស្ថានភាពងាយរងគ្រោះច្រើន ទៅតាមយេនឌ័រ ឬក៏សកម្មភាពការងារផ្សេងគ្នារបស់គេ។

# ត្រូវចាំថា

ហានិភ័យមានទំហំធំធេង ត្រូវតែធ្វើការ
វាយតម្លៃឲ្យបានទៀងទាត់ ជាពិសេស
ប្រសិនបើកម្រិតនៃការគំរាមកំហែងពី
បរិស្ថានការងារមានការប្រែប្រួល។

# ៣. វាយតម្លៃការគំរាមកំហែង និងវិភាគទៅលើឧបទ្ទវហេតុសន្តិសុខសុវត្ថិភាព

## តើនឹងត្រូវធ្វើដូចម្តេចខ្លះ

ពិនិត្យមើលការគំរាមកំហែងផ្សេងៗ។

ពិនិត្យនិងកំណត់អាទិភាពនៃការគំរាមគំហែង មានជាក់ស្តែង ឬក៏នឹងអាចកើតមាន។

ដើម្បីកំណត់អាទិភាពនៃការគំរាមកំហែងនោះ ត្រូវប្រើលក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងនេះ៖

- ការគំរាមកំហែងដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត

  ឬ

- ការគំរាមកំហែងនោះតើអាចនឹងមានលក្ខណៈធ្ងន់ធ្ងរកម្រិតណា

## ១. ការគំរាមកំហែងមានចរិតលក្ខណៈទូទៅ

### ហេតុការណ៍ជុំវិញការគំរាមកំហែង

តើហេតុការណ៍នៃការគំរាមកំហែងនោះ កើតឡើងយ៉ាងដូចម្តេចខ្លះ ?

តើគេនិយាយអ្វីខ្លះ នៅពេលណា និងដោយរបៀបណា ?

តើគេប្រើភាសា និងសំឡេងយ៉ាងដូចម្តេចខ្លះ ?

តើវាកើតឡើង ក្រោយពីអ្នកការពារសិទ្ធិមនុស្សបានធ្វើសកម្មភាពថ្មីដែរ ឬទេ ?

### លំនាំនៃការគំរាមកំហែង

**១ ) លំនាំនោះ មានដូចជា៖**

ធ្លាប់មានការគំរាមកំហែងជាហូរហែរតាមទូរស័ព្ទ ឬផ្ញើសារ។

ធ្លាប់មានការតាមឃ្លាំមើលអ្នកការពារសិទ្ធិមនុស្ស និងឬ ក្រុមគ្រួសាររបស់ពួកគេ។

ធ្លាប់មានការសួរនាំអំពីអ្នកការពារសិទ្ធិមនុស្ស ពីសំណាក់អាជ្ញាធរ។

ធ្លាប់មានការចាប់ឃុំខ្លួនអ្នកការពារសិទ្ធិមនុស្ស។

**២ ) លំនាំមួយចំនួន មានពាក់ព័ន្ធទៅនឹង៖**

ធ្លាប់គំរាមកំហែងរបៀបណា

មធ្យោបាយអ្វីខ្លះ ដែលគេប្រើដើម្បីគំរាមកំហែង ( ជាបុគ្គល តាមរយៈទូរស័ព្ទ ។ល។ )

ពេលវេលានៃការគំរាមកំហែងនោះ (ថ្ងៃណាក្នុងមួយសប្តាហ៍ និងនៅពេលណា )។

ជនដែលធ្វើការគំរាមកំហែងនោះ (ប្រសិនបើស្គាល់ )។

ទីកន្លែងដែលគេបានធ្វើការគំរាមកំហែង។

ហេតុការណ៍មុនកើតមានការគំរាមកំហែង ឧទា. មានដូចជា សកម្មភាពថ្មី ការចេញសេចក្តីប្រកាសព័ត៌មាន។ល។៕

## គោលដៅនៃការគំរាមកំហែង

គោលដៅនៃការគំរាមកំហែងនោះ តើគេចង់បានអ្វី ?

តើការគំរាមកំហែងនោះ ស្តែងឲ្យឃើញច្បាស់ទេថា ជនល្មើសចង់បានអ្វីពីអ្នកការពារសិទ្ធិមនុស្ស ?

ប្រសិនបើវាមិនស្តែងឲ្យឃើញច្បាស់ទេត្រូវវិភាគទៅលើសកម្មភាពអ្វីខ្លះដែលគេបានគ្រោងធ្វើ ឬដែលបានធ្វើនាពេលថ្មីៗនេះ ដើម្បីបញ្ជាក់ពីការគំរាមកំហែងនោះ។

## អ្នកគំរាមកំហែង

តើអ្នកណាជាអ្នកគំរាមកំហែង ?

តើការងាររបស់អ្នកការពារសិទ្ធិមនុស្សធ្វើឲ្យប៉ះពាល់ដល់បុគ្គល ឬក្រុមណាមួយ ដែរ ឬទេ ?

តើការងាររបស់អ្នកការពារសិទ្ធិមនុស្សនោះ ធ្វើឲ្យប៉ះពាល់ដល់បុគ្គលដែលមានអំណាចដែរ ឬទេ ?

តើអ្នកណាទាមទារបញ្ឈប់អ្នកការពារសិទ្ធិមនុស្ស មិនឲ្យអនុវត្តសកម្មភាពការងាររបស់ខ្លួន ?

គិតពិចារណាមើល តើសញ្ញានៃការគំរាមកំហែងនោះ គឺពិតជាចេញពីឈ្មោះបុគ្គល ឬអង្គការចាត់តាំងណាមួយដែរ ឬទេ។

បើស្គាល់អ្នកគំរាមកំហែងនោះ គួរតែពិចារណាថា តើជននោះមានធនធានគ្រប់គ្រាន់អាចធ្វើការគំរាមកំហែងនោះមែនដែរ ឬទេ។ បើមែន ជនល្មើសនឹងបង្កើនការគំរាមឈានដល់ការវាយប្រហារ។

## ការយល់ដឹងពីការគំរាមកំហែង

តើការគំរាមកំហែងនោះ នឹងអាចយកមកអនុវត្តមែន ឬទេ?

វាយតម្លៃពីទំហំនៃការគំរាមកំហែង ដែលគេអាចយកមកអនុវត្ត គឺជាការលំបាក ពីព្រោះអ្នកការពារសិទ្ធិមនុស្សអាចនឹងដឹងមិនប្រាកដ ១០០% បាននោះទេ។

ដើម្បីឆ្លើយតបទៅនឹងការគំរាមនេះ គួរគិតពិចារណាពីប្រវត្តិនៃការវាយប្រហារដែលធ្លាប់មានទៅលើអ្នកការពារសិទ្ធិមនុស្សនៅក្នុងប្រទេស កម្រិតនៃការគំរាមកំហែងរបស់ជនល្មើស និងកម្រិតនិទណ្ឌភាពរបស់ជនល្មើស។

ក្នុងករណីមានភាពស្រពិចស្រពិល ឬ មានការសង្ស័យ គួរជ្រើសយកជម្រើសណាមួយ ដែលទំនងជាមានសុវត្ថិភាពបំផុត។

រាល់ការគំរាមកំហែងទាំងឡាយ ត្រូវតែយកមកគិតគូរពិចារណាឲ្យបានហ្មត់ចត់ និងចាត់ការដើម្បីបញ្ចៀសហានិភ័យផ្សេងៗ។

# ២) ការគំរាមកំហែងដែលមានចរិតលក្ខណៈជាក់លាក់

## តើនឹងត្រូវធ្វើអ្វីខ្លះ ក្នុងករណីដែលមានការតាមឃ្លាំមើល

រៀបចំផែនការ និងរកដំណោះស្រាយ មុននឹងបញ្ហានោះមកដល់ ឧទា. ចេះប្រើទាំងអស់គ្នានូវពាក្យនិងឃ្លាសម្ងាត់ ឬ passwords សម្រាប់សារបំភ័ន្តអក្ខរៈជាមួយក្រុមគ្រួសារ ឬសហការី។ ត្រូវមានទូរស័ព្ទពិសេសមួយ ដើម្បីប្រើប្រាស់ និងទំនាក់ទំនងក្នុងករណីបន្ទាន់ ដែលមិនបញ្ជាក់ពីឈ្មោះអ្នកប្រើ ហើយត្រូវត្រៀមរៀបចំរថយន្តបង្ការក្នុងករណីមានអាសន្ន។

វាយតម្លៃអំពីគោលបំណងនៃការតាមឃ្លាំមើល៖ តើការតាមឃ្លាំមើលនោះ ធ្វើឡើងគ្រាន់តែដើម្បីជាការប្រមូលព័ត៌មាន ឬជាការបំភិតបំភ័យ ឬក៏ជាការរៀបចំចាប់ខ្លួននរណាម្នាក់ ឬយ៉ាងណា?

ជៀសវាងដាក់នរណាម្នាក់ ឲ្យស្ថិតក្នុងស្ថានភាពប្រឈមនឹងហានិភ័យ។

ធ្វើសកម្មភាពដូចសព្វមួយដង ឧទា. ពេលព្រឹក ចេញក្រៅផ្ទះក្រឡេកមើលនាយអាយ ដូចជាយកសម្រាមទៅចោល ឬឲ្យនរណាម្នាក់លបមើលពីក្រោយជាសម្ងាត់ថាតើមានអ្វីកើតឡើងក្រោយដើរចេញពីផ្ទះ។

ផ្លាស់ប្តូរទម្លាប់៖ ធ្វើការងារ ត្រូវចេះលៃលក ទាំងទៅទាំងមក ប្រសិនបើអាចធ្វើបាន ត្រូវប្តូរទិសដៅធ្វើដំណើរ និងពេលម៉ោងធ្វើការខុសគ្នា មិនត្រូវបង្កើតជាទម្លាប់អាចឲ្យគេទាយដឹងមុនបានឡើយ។

## អ្វីដែលមិនគួរធ្វើ នៅពេលដែលស្ថិតក្រោមការតាមឃ្លាំមើល

មិនត្រូវជជែកវែកញែកតវ៉ាជាមួយនរណាម្នាក់ ដែលទំនងជាកំពុងតាមដានឃ្លាំមើលពីសកម្មភាពរបស់អ្នកឡើយ។

មិនត្រូវប្រើទម្លាប់ចាស់ តាមបែបនិយាយឌឺដងដាក់អ្នកតាមឃ្លាំមើលយើងឡើយ។

## តើនឹងត្រូវធ្វើដូចម្តេចខ្លះ ក្នុងករណីដែលមានការចាប់ខ្លួន ឬការឃុំខ្លួន

នគរបាល ត្រូវតែប្រាប់យើងភ្លាម ពីមូលហេតុនៃការចាប់ខ្លួន ការឃុំខ្លួន អ្នកការពារសិទ្ធិមនុស្ស។

ក្រោយពីការឃុំខ្លួនបានពីរថ្ងៃ នគរបាលត្រូវតែធ្វើការចោទប្រកាន់ ឬក៏ដោះលែងអ្នកការពារសិទ្ធិមនុស្សរូបនោះ។

ក្រោយពីការឃុំខ្លួនបាន២៤ម៉ោង អ្នកការពារសិទ្ធិមនុស្សរូបនោះ ត្រូវតែបានជួបជាមួយមេធាវី ឬក៏បុគ្គលណាម្នាក់ តាមការចង់បានរបស់គាត់។ ប្រសិនបើគាត់គ្មានលទ្ធភាពរកមេធាវីបានទេនោះ មានអង្គការជំនួយផ្នែកច្បាប់មួយចំនួន ដែលអាចជួយគាត់បាន។

អ្នកការពារសិទ្ធិមនុស្សមិនគួរសារភាពពីអ្វីមួយ ដែលពួកគេមិនបានធ្វើនោះឡើយ។ ប្រសិនបើមានការប្រើប្រាស់អំពើទារុណកម្ម ដើម្បីបង្ខំឲ្យបុគ្គលនោះសារភាព ចម្លើយសារភាពនោះគ្មានសុពលភាពឡើយ។

ក្រោយពីការចាប់ខ្លួននោះភ្លាម អ្នកការពារសិទ្ធិមនុស្ស ត្រូវតែបានជួបជាមួយនឹងចៅក្រម។ ចៅក្រមនឹងបើកការស៊ើបអង្កេតទៅលើករណីនោះ ហើយត្រូវតែប្រាកដថា អ្នកការពារសិទ្ធិមនុស្សរូបនោះ ទទួលបានការប្រព្រឹត្តមកលើគាត់ដោយត្រឹមត្រូវ។

អ្នកការពារសិទ្ធិមនុស្ស មានសិទ្ធិផ្តល់ដំណឹងដល់ក្រុមគ្រួសាររបស់គាត់ ក្រោយការចាប់ខ្លួន។

អ្នកការពារសិទ្ធិមនុស្ស គួរប្រាប់ទៅមេធាវី ប្រសិនបើសិទ្ធិរបស់ពួកគាត់ត្រូវបានបដិសេធ។

អ្នកការពារសិទ្ធិមនុស្ស គួរពិនិត្យមើលលើកំណត់ហេតុ មុនពេលចុះហត្ថលេខា ឬផ្តិតមេដៃ។ ប្រសិនបើគាត់មិនចេះអាន ត្រូវមាននរណាម្នាក់អានឯកសារនោះឲ្យគាត់ស្តាប់ មុនពេលផ្តិតមេដៃ។

អ្នកការពារសិទ្ធិមនុស្ស មិនត្រូវបានគេបង្គាប់ឲ្យបង់លុយជាថ្នូរនឹងការដោះលែងបានឡើយ។

អ្នកការពារសិទ្ធិមនុស្ស ត្រូវរាយការណ៍ប្រាប់មេធាវីរបស់ខ្លួន ឬប្រាប់ព្រះរាជអាជ្ញាអំពីអំពើទារុណកម្ម ការធ្វើទុក្ខទោស ឬអំពីការគំរាមកំហែងណាមួយ ក្នុងអំឡុងពេលចាប់ខ្លួន ឬក្នុងពេលសួរចម្លើយ ពីសំណាក់មន្ត្រីនគរបាល។

## ៣ ) ឧបទ្ទវហេតុសន្តិសុខសុវត្ថិភាព

### សំណួរដែលត្រូវសួរ ក្នុងករណីដែលកើតមានឧបទ្ទវហេតុពីសន្តិសុខសុវត្ថិភាព

តើមានរឿងអ្វីកើតឡើង ?

តើឧបទ្ទវហេតុនោះ កើតឡើងនៅពេលណា ?

តើឧបទ្ទវហេតុនោះ កើតឡើងនៅកន្លែងណា ?

តើមាននរណាខ្លះ ទទួលរងផលប៉ះពាល់ ?

តើមានការពាក់ព័ន្ធនឹងអំពើហិង្សាលើស្ត្រីដែរ ឬទេ ?

ក្នុងករណីដែលមានការបំពារបំពាន តើអ្នកណាជាអ្នកប្រព្រឹត្ត ?

តើដើមរឿងនោះកើតចេញពីអ្វី៖ ដោយសារតែការងារអ្នកការពារសិទ្ធិមនុស្ស ឬក៏ដោយសារតែហេតុផលផ្សេងទៀត ឧទា. ដូចជា រឿងផ្ទាល់ខ្លួន ឬក៏ជារឿងនយោបាយ ។ល។ ?

### តើនឹងត្រូវធ្វើដូចម្តេចខ្លះ ក្នុងករណីមានការពាក់ព័ន្ធទៅនឹងឧបទ្ទវហេតុពីសន្តិសុខសុវត្ថិភាព

ត្រូវកត់ត្រាភ្លាមៗ នូវហេតុការណ៍ និងឧបទ្ទវហេតុពីសន្តិសុខសុវត្ថិភាពនោះ។

ត្រូវមានសៀវភៅសម្រាប់កត់ត្រាអំពីឧបទ្ទវហេតុសន្តិសុខសុវត្ថិភាព ដែលសៀវភៅនេះ គឺសម្រាប់តែកត់ត្រាពីការគំរាមកំហែង ឬឧបទ្ទវហេតុសុវត្ថិភាពនីមួយៗប៉ុណ្ណោះ។

ប្រសិនបើធ្វើការជាក្រុម ត្រូវប្រាកដថា សមាជិកក្នុងក្រុមទាំងអស់ ត្រូវតែកត់ត្រាអំពីឧបទ្ទវហេតុសន្តិសុខសុវត្ថិភាពណាមួយ ក្នុងសៀវភៅនោះ។

ត្រូវពិភាក្សាអំពីឧបទ្ទវហេតុសន្តិសុខសុវត្ថិភាពនោះជាមួយសហការី ឬជាមួយនរណាម្នាក់ដែលអ្នកជឿទុកចិត្ត។

ត្រូវវិភាគអំពីឧបទ្ទវហេតុសន្តិសុខសុវត្ថិភាព និងធ្វើការសម្រេចចិត្តថាតើត្រូវចាត់ការអ្វីខ្លះ។

ត្រូវពិនិត្យរៀបចំផែនការសន្តិសុខសុវត្ថិភាពឡើងវិញ ដើម្បីឲ្យដល់កម្រិតមួយកាន់តែមានភាពរឹងមាំ ប្រសិនបើឃើញថាចំនួនឧបទ្ទវហេតុសុវត្ថិភាពមានការកើនក្នុងរយៈពេលមួយដ៏ខ្លី។

លំនាំនៃឧបទ្ទវហេតុដដែលៗខាងសន្តិសុខសុវត្ថិភាព អាចមានន័យថា អ្នកកំពុងស្ថិតក្រោមការតាមឃ្លាំមើល ពីសំណាក់ អាជ្ញាធរ ឬពីជនដទៃទៀត។

## តើមានអ្នកណាខ្លះ អាចជួយដល់អ្នកការពារសិទ្ធិមនុស្សបាន ក្នុងករណីដែលគាត់ប្រឈមនឹងឧបទ្ទវហេតុពីសន្តិសុខសុវត្ថិភាព

មានអង្គការសង្គមស៊ីវិលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានមួយចំនួន អាចជួយដល់អ្នកការពារសិទ្ធិមនុស្សបាន នៅពេលដែលពួកគេប្រឈមនឹងបញ្ហាសន្តិសុខសុវត្ថិភាព ជាពិសេសតាមរយៈជំនួយផ្នែកច្បាប់ (សូមមើលជំពូក VI)។

នៅកម្រិតអន្តរជាតិ អង្គការសហប្រជាជាតិ មានយន្តការការពារជាក់លាក់មួយចំនួន ដែលអាចទទួលបណ្តឹងស្តីពីការរំលោភសិទ្ធិមនុស្សផ្សេងៗបាន។

- ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស តាមឃ្លាំមើល និងរាយការណ៍អំពីករណីរំលោភបំពានលើអ្នកការពារសិទ្ធិមនុស្ស ដោយរួមទាំង តាមការសងសឹកលើអ្នកណាដែលសហការជាមួយនឹងអង្គការសហប្រជាជាតិ លើបញ្ហាសិទ្ធិមនុស្ស (ព័ត៌មានលម្អិត សូមមើលជំពូក VII)។
- បុគ្គលក្រុម អង្គការសង្គមស៊ីវិល ស្ថាប័នអន្តររដ្ឋាភិបាល ឬស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ អាចដាក់បញ្ជូនព័ត៌មានទៅនីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ អត្តសញ្ញាណនិងប្រភពព័ត៌មានត្រូវរក្សាជាការសម្ងាត់។ការបញ្ជូនឯកសារទាំងអស់នោះ អាចផ្ញើតាមរយៈប៉ុស្តិ៍ប្រៃសណីយ៍ ឬ តាមរយៈអ៊ីមែល((ព័ត៌មានលម្អិត សូមមើលជំពូក VI)។

# ៤. ការវាយតម្លៃ និងពង្រឹងសមត្ថភាព

## តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីបង្កើនកម្រិតសមត្ថភាពអ្នកការពារសិទ្ធិមនុស្ស និងកាត់បន្ថយភាពងាយរងគ្រោះ

វាយតម្លៃ និងកែលម្អ ប្រសិនបើមានការចាំបាច់៖

១ ការចែករំលែកព័ត៌មានផ្ទាល់ខ្លួន

២ មធ្យោបាយប្រាស្រ័យទាក់ទងគ្នា

៣ មធ្យោបាយធ្វើដំណើរ

៤ ការចងក្រងជាបណ្តាញ

៥ ការគ្រប់គ្រងព័ត៌មាន ឬឯកសារជាលាយលក្ខណ៍អក្សរ និងឌីជីថល

៦ ការការពារលំនៅដ្ឋាន និងការិយាល័យ

៧ ការការពារក្រុមគ្រួសារ

៨ ការគ្រប់គ្រងភាពតឹងក្នុងអារម្មណ៍

## ១. តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីពង្រឹងការចែករំលែកព័ត៌មានផ្ទាល់ខ្លួន

ត្រូវប្រាប់ក្រុមគ្រួសារ និងមិត្តភក្តិ ឲ្យបានដឹងពីសកម្មភាពការងាររបស់ខ្លួន ឧទា. ដូចជា ទីកន្លែង ជួបជាមួយអ្នកណា ប្រើរយៈពេលប៉ុន្មាន ។ល។

ត្រូវណែនាំប្រាប់ក្រុមគ្រួសារឲ្យបានដឹងជាមុនថា ត្រូវធ្វើដូចម្តេចខ្លះ ករណីដែលឧបទ្ទវហេតុពាក់ព័ន្ធនឹងសន្តិសុខសុវត្ថិភាពកើតឡើង។

## ២. តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីពង្រឹងមធ្យោបាយទំនាក់ទំនង

ត្រូវមានមធ្យោបាយទំនាក់ទំនងដែលល្អ គត់ហ្មត់ និងមានប្រសិទ្ធភាព។

ប្រសិនបើពុំមានលទ្ធភាពមានទូរស័ព្ទ (ស្មាតហ្វូន) សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនទេនោះ ត្រូវរកអ្នកណាម្នាក់ដែលអាចជឿទុកចិត្តបាន ធ្វើជាជំនួបង្គោលដើម្បីធ្វើទំនាក់ទំនងជាមួយអង្គការនានា ក្នុងករណីដែលមានបញ្ហាពីសន្តិសុខសុវត្ថិភាពកើតឡើង។

នៅពេលប្រើប្រាស់ទូរស័ព្ទដៃ ត្រូវពិនិត្យមើលកម្មវិធី (Privacy Setting) បន្ទាប់មក ត្រូវដាក់កំណត់យកជាអាទិភាពទៅលើការប្រើប្រាស់កម្មវិធី ដែលមានសុវត្ថិភាព ។ល។

ទូរស័ព្ទត្រូវសាកថ្មគ្រប់គ្រាន់ មានទឹកប្រាក់គ្រប់គ្រាន់សម្រាប់ហៅចេញ និងភ្ជាប់លេខជាស្រេច សម្រាប់ទាក់ទំនងក្នុងគ្រាអាសន្ន។

## ៣. តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យការធ្វើដំណើរមានសុវត្ថិភាព

ជៀសវាងការធ្វើដំណើរតែម្នាក់ឯង។ ត្រូវធ្វើដំណើរដោយមានគ្នាពីម្នាក់ ឬពីរនាក់ឡើងទៅ។

ក្នុងករណីធ្វើដំណើរជាក្រុម កុំធ្វើដំណើរផ្តុំគ្នា។

មធ្យោបាយដែលល្អ និងមានសុវត្ថិភាព គឺការធ្វើដំណើរតាមផ្លូវគោក។

ជៀសវាងការធ្វើដំណើរពេលយប់។

## ៤. តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីពង្រឹងការចងក្រងជាបណ្តាញ

ត្រូវចេះចងក្រងជាបណ្តាញជាមួយអ្នកការពារសិទ្ធិមនុស្សដទៃផ្សេងទៀត ប្រព័ន្ធផ្សព្វផ្សាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអង្គការនានា។

ត្រូវដឹងថា តើបណ្តាញអ្នកការពារសិទ្ធិមនុស្សនីមួយៗ អាចជួយផ្តល់សេវាការពារអ្វីខ្លះ។

ការមានបណ្តាញអ្នកការពារសិទ្ធិមនុស្សដទៃផ្សេងទៀត ជួយគាំទ្រ ឬមានប្រព័ន្ធមួយឆ្លើយតបរួមគ្នា គឺជាការល្អ ក្នុងករណីដែលមានការវាយប្រហារទៅលើអ្នកការពារសិទ្ធិមនុស្ស។

## ៥. តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីពង្រឹងការគ្រប់គ្រងឯកសារ ឬព័ត៌មានជាលាយលក្ខណ៍អក្សរ និងឯកសារជាឌីជីថល

ត្រូវដឹងថា ការបែកធ្លាយព័ត៌មានរសើបអាចបង្កឲ្យមានការគំរាមកំហែងលើសន្តិសុខសុវត្ថិភាព។

ត្រូវថតចម្លង រាល់ឯកសារទាំងអស់។

មិនត្រូវទុកដាក់ឯកសារថតចម្លងនោះ នៅកន្លែងតែមួយឡើយ។

ត្រូវចេះទុកដាក់ឯកសារសម្ងាត់ និងឯកសារផ្ទាល់ខ្លួននៅកន្លែងមានសុវត្ថិភាព ដូចជាចាក់សោរទុកក្នុងថតតុ ឧទា. ដូចជា សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ និងសញ្ញាប័ត្របញ្ជាក់ការសិក្សា ត្រូវតែទុកដាក់នៅកន្លែងណាមួយដែលមានសុវត្ថិភាព។

ក្នុងនាមជាសមាជិកបណ្តាញសហគមន៍ ត្រូវរក្សាទុកព័ត៌មានទាក់ទងនឹងសកម្មភាពការងារបណ្តាញ ឲ្យមានសុវត្ថិភាព ជៀសវាងការបាត់បង់ ត្រូវគេលួច ឬត្រូវគេបំផ្លាញ។

**ចំណេះដឹងផ្នែករក្សាឯកសារឌីជីថល**

ប្រសិនបើអាចធ្វើបាន ត្រូវចេះពីបច្ចេកវិទ្យាព័ត៌មាន (IT) ដូចជា កុំព្យូទ័រ ទូរស័ព្ទដៃ ។ល។

ប្រសិនបើធ្វើការជាក្រុម ត្រូវរកសមាជិកល្អណាម្នាក់ ដែលយល់ដឹងពីកម្រិតប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីជួយដល់ក្រុមរបស់ខ្លួន។

**ការប្រើប្រាស់កម្មវិធីឌីជីថល**

ប្រើប្រាស់កម្មវិធីដែលធានាការសំងាត់។

ប្រសិនបើអាច ពេលផ្ញើព័ត៌មានរសើបតាមអ៊ីមែល ត្រូវប្រើសារបំភ័ន្តអក្ខរៈ (កូដ) ។

រាល់មធ្យោបាយទំនាក់ទំនងទាំងអស់ ត្រូវដាក់លេខសម្ងាត់រឹងមាំ ហើយផ្លាស់ប្តូរវាឲ្យបានញឹកញាប់។

**ការប្រើប្រាស់បណ្តាញសង្គម**

ត្រូវយល់ដឹង និងវិភាគពីហានិភ័យសន្តិសុខសុវត្ថិភាព ពាក់ព័ន្ធក្នុងការប្រើប្រាស់គេហទំព័របណ្តាញសង្គម។

ការពារទិន្នន័យ នៅពេលប្រើប្រាស់គេហទំព័របណ្តាញសង្គម។

**ការចែករំលែកព័ត៌មានរសើប**

ជៀសវាងពិភាក្សា ឬចែករំលែកព័ត៌មានរសើប តាមរយៈទូរស័ព្ទ ឬផ្ញើអ៊ីមែល។

ជៀសវាងការនិយាយពីឈ្មោះ និងទីកន្លែង នៅពេលនិយាយទូរស័ព្ទជាមួយនរណាម្នាក់។

**ព័ត៌មានរសើប**

ប្រសិនបើចាំបាច់ ត្រូវបំផ្លាញព័ត៌មានរសើបចោលទាំងអស់។

# បម្រាម

បច្ចុប្បន្ន ការប្រើប្រាស់បណ្តាញទូរគមនាគមន៍ និងអ៊ីនធឺណិត បានធ្វើឲ្យការប្រាស្រ័យទាក់ទងគ្នា មានលក្ខណៈងាយស្រួល ប៉ុន្តែវាក៏ធ្វើឲ្យការតាមឃ្លាំមើលកាន់តែមានភាពងាយស្រួលណាស់ដែរ។

រាល់ការប្រើទូរស័ព្ទ ការផ្ញើសារ ការផ្ញើអ៊ីមែល ការសន្ទនាមានរូបភាពវីដេអូ (video chat) និងការប្រើប្រាស់សារតាមបណ្តាញសង្គមផ្សេងៗ ក៏សុទ្ធតែគេអាចតាមដានបានទាំងអស់។

មធ្យោបាយដែលមានសុវត្ថិភាពបំផុត ក្នុងការប្រាស្រ័យទាក់ទងគ្នា គឺការជួបដោយផ្ទាល់ ដោយមិនចាំបាច់មានកុំព្យូទ័រ ឬទូរស័ព្ទជាប់មកជាមួយ។

## ៦. តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីការពារលំនៅដ្ឋាន និងការិយាល័យរបស់អ្នក

ទ្វារ និងបង្អួច ត្រូវចាក់សោរជាប់ជានិច្ច។

ប្រសិនបើមានមធ្យោបាយហិរញ្ញវត្ថុ ត្រូវតំឡើង និងប្រើប្រាស់កាមេរ៉ាសុវត្ថិភាព បំពាក់ឧបករណ៍បន្លឺសំឡេង និងដាក់អំពូលភ្លើងនៅខាងក្រៅ។

ប្រើប្រាស់សោរ ដើម្បីការពារសុវត្ថិភាពកន្លែងសំខាន់ៗ ឧទា. ដូចជា ថតតុទូ តុការិយាល័យ ។ល។

មិនត្រូវឲ្យភ្ញៀវឃើញកូនសោរ ឬប្រើប្រាស់កូនសោរឡើយ។ ត្រូវរក្សាទុកកូនសោរទាំងអស់នៅក្នុងថតតុដោយមានចាក់សោរ។

ត្រូវត្រួតពិនិត្យរាល់ភ្ញៀវចេញចូលការិយាល័យរបស់អ្នកនិងសួរនាំពីអត្តសញ្ញាណរបស់ភ្ញៀវ។

គួរគិតពិចារណាមានឆ្កែយាមផ្ទះ

## ៧. តើនឹងត្រូវធ្វើដូចម្តេចខ្លះ ដើម្បីការពារសមាជិកគ្រួសាររបស់អ្នក

សមាជិកគ្រួសារត្រូវដឹងពីការងាររបស់អ្នកការពារសិទ្ធិមនុស្សធ្វើអ្វី តើមានទាក់ទងទៅនឹងរឿងអ្វី ពាក់ព័ន្ធនឹងបញ្ហាសន្តិសុខសុវត្ថិភាពយ៉ាងដូចម្តេចខ្លះ។

ស្ថានភាពគ្រួសារនីមួយៗមានលក្ខណៈខុសប្លែកពីគ្នា ឧទា. ដូចជា គ្រួសារខ្លះមានកូន គ្រួសារខ្លះគ្មានកូន មានតិច មានច្រើន មានចាស់ មានក្មេង រស់នៅក្នុងផ្ទះជាមួយគ្នា ។ល។ ដូច្នេះ ត្រូវបង្កើតជាគោលការណ៍ជាក់លាក់មួយពាក់ព័ន្ធនឹងសន្តិសុខសុវត្ថិភាព ដើម្បីឲ្យអនុវត្តបានស្របគ្នាក្នុងគ្រួសារ។

ត្រូវប្រាកដថា ដំណើរការសន្តិសុខសុវត្ថិភាព មិនមែនដាក់កំហិតឲ្យសមាជិកគ្រួសារត្រូវតែប្រើប្រាស់នោះឡើយ តែក៏ត្រូវពិភាក្សាឯកភាពគ្នាផងដែរ។

សមាជិកគ្រួសារ ទាំងក្មេង ទាំងចាស់ ត្រូវតែចូលរួមពិភាក្សាពីដំណើរការនេះ ជាពិសេសស្ត្រី ពីព្រោះស្ត្រីអាចនឹងប្រឈមហានិភ័យផ្សេងៗ ជួនកាល អាចនឹងប្រឈមហានិភ័យដែលមានកម្រិតខ្ពស់ជាងក៏ថាបាន។

សមាជិកគ្រួសារ ត្រូវដឹងពីរបៀបឆ្លើយតបដោះស្រាយទៅនឹងគ្រោះថ្នាក់ ក្នុងករណីបន្ទាន់ និងមានគ្រាអាសន្ន។ ជាពិសេស ត្រូវដឹងថា តើត្រូវទូរស័ព្ទទៅនរណាមុនគេ ក្នុងករណីមានអាសន្ន និងថាតើប្រព័ន្ធសេវាសាធារណៈមួយណាដែលមានប្រយោជន៍ ហើយតើសាច់ញាតិ ឬអ្នកជិតខាងណាដែលអាចជឿទុកចិត្ត និងអាចជួយយើងបាន។

សមាជិកគ្រួសារ ត្រូវតែស្គាល់លេខទូរស័ព្ទរបស់សមាជិកសំខាន់ៗ ទុកសម្រាប់ទាក់ទងក្នុងគ្រាមានអាសន្ន។ ជាពិសេស កូនៗអាចទាក់ទងទៅឪពុកម្តាយរបស់ខ្លួនបានគ្រប់ពេល។

សមាជិកគ្រួសារទាំងអស់ គួរតែប្រយ័ត្នប្រយែងក្នុងការចែករំលែកព័ត៌មាន។

សមាជិកគ្រួសារ គួរតែប្រយ័ត្នប្រយែង ពេលប្រើប្រាស់ទូរស័ព្ទ អ៊ីនធឺណិត និងបណ្តាញសង្គមផ្សេងៗ។

សមាជិកគ្រួសារ ត្រូវតែយល់ដឹងពីបរិស្ថានរស់នៅជុំវិញខ្លួន ត្រូវស្គាល់ផ្លូវ និងស្គាល់អ្នកជិតខាង។

សមាជិកគ្រួសារ ត្រូវតែចេះសំគាល់មើលពីជនចម្លែក និងកាលៈទេសៈដែលគួរឲ្យសង្ស័យ កត់យកព័ត៌មាននោះ ហើយប្រាប់សមាជិកគ្រួសារឯទៀតឲ្យបានដឹង។

## ៨. តើនឹងត្រូវធ្វើអ្វីខ្លះ ក្នុងគ្រាមានភាពតានតឹងក្នុងអារម្មណ៍

ខាងក្រោមនេះ គឺជាគំនិតខ្លះ ដើម្បីដោះស្រាយភាពតានតឹងក្នុងអារម្មណ៍ ៖

- ស្វែងរកជំនួយ និងស្វែងរកការជួយគាំទ្រផ្សេងៗ ពីបណ្តាញអ្នកការពារសិទ្ធិមនុស្សដទៃទៀត។
- ជជែកពិភាក្សាជាមួយមិត្តភក្តិ ឬមនុស្សដែលខ្លួនអាចជឿទុកចិត្តបាន។
- ដើរលំហែរកាយជាមួយមិត្តភក្តិ
- ប្រលែងលេងជាមួយក្មេងៗ
- ដើរកំសាន្ត
- ធ្វើលំហាត់ប្រាណ
- បិទទូរស័ព្ទចោល ២ ទៅ ៣ ម៉ោង
- ធ្វើសមាធិ
- ស្តាប់តន្ត្រី ( ចម្រៀង )
- ធ្វើម៉ាស្សា
- អង្គុយស្ងៀមស្ងាត់ រយៈពេល២ ទៅ ៣ ម៉ោង និងព្យាយាមសម្រួលឥរិយាបថ
- គេងឲ្យបានច្រើន ទោះបីជាពេលថ្ងៃក៏ដោយ

# ៥. ការរៀបចំធ្វើផែនការពីសន្តិសុខសុវត្ថិភាព

ការធ្វើផែនការសន្តិសុខសុវត្ថិភាព សំដៅដល់ការកាត់បន្ថយហានិភ័យផ្សេងៗ។

ផែនការពីសន្តិសុខសុវត្ថិភាព ត្រូវតែមានរួមបញ្ចូល វិធានការបង្ការទប់ស្កាត់ និងគ្រប់គ្រងស្ថានភាពជាក់លាក់។

**ផែនការសន្តិសុខសុវត្ថិភាព ត្រូវផ្អែកលើ៖**




- ការវាយតម្លៃពីហានិភ័យ



- ការវាយតម្លៃ និងការវិភាគពីការគំរាមកំហែង



- ការវាយតម្លៃពីកម្រិតសមត្ថភាព ឬភាពងាយរងគ្រោះផ្សេងៗ

# បម្រាម

គ្មានការបណ្តុះបណ្តាល ឬការធ្វើផែនការណាមួយ ដែលអាចជួយឲ្យអ្នកការពារសិទ្ធិមនុស្សមានសុវត្ថិភាពទាំងស្រុងនោះឡើយ ប៉ុន្តែ ការយល់ដឹងពីការគំរាមកំហែងដែលអាចនឹងកើតមាន និងការពង្រឹងសមត្ថភាព នាំឲ្យអ្នកការពារសិទ្ធិមនុស្សអាចកាត់បន្ថយហានិភ័យរបស់ខ្លួនបាន។

# តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីរៀបចំបង្កើតផែនការពីសន្តិសុខសុវត្ថិភាព

## ១. តើនឹងត្រូវធ្វើអ្វីខ្លះ នៅពេលអ្នកធ្វើការឲ្យអង្គការ

សហការីទាំងអស់ ត្រូវជួបជុំគ្នា ដើម្បីពិភាក្សា និងរៀបចំធ្វើបញ្ជីពីហានិភ័យ ដែលសង្គមស៊ីវិលប្រឈម និងមនុស្សដែលធ្វើការនៅក្នុងអង្គការប្រឈម។

រៀបចំកសាងពីការយល់ដឹងអំពីសន្តិសុខសុវត្ថិភាព និងការប្ដេជ្ញាចិត្ត ដើម្បីប្រកាន់ខ្ជាប់វិធានការសន្តិសុខសុវត្ថិភាពផ្សេងៗ។

ជំរុញឲ្យមានការចូលរួមពីបុគ្គលិកគ្រប់គ្នា។ ឧទា. បុគ្គលិកផ្នែកគាំទ្រ ដូចជា បុគ្គលិកផ្នែកទទួលភ្ញៀវ និងអ្នកបើកបរ អាចនឹងមិនស្ថិតក្នុងហានិភ័យខ្ពស់ប៉ុន្មានទេ ប៉ុន្តែពួកគេអាចជាមនុស្សមុនគេ ដែលឆាប់យល់ដឹងពីឧបទ្ទវហេតុសន្តិសុខសុវត្ថិភាពផ្សេងៗ។

ជំរុញនិងលើកទឹកចិត្តដល់បុគ្គលិកគ្រប់រូបចូលរួមផ្តល់មតិយោបល់ និងពិចារណាឲ្យបានហ្មត់ចត់។

មុននឹងចេញបំពេញភារកិច្ច អ្នកការពារសិទ្ធិមនុស្ស ត្រូវពិភាក្សាគ្នាពីពិធីសាស្រ្តផ្សេង គួរធ្វើជាក្រុម ឬធ្វើជាមួយបុគ្គលម្នាក់ៗដែលរងគ្រោះដោយអំពើហិង្សា ឬសាក្សី ដើម្បីកាត់បន្ថយហានិភ័យដែលអាចនឹងប្រឈម ដោយសារតែពួកគាត់បានជួបសម្ភាសន៍ជាមួយអ្នកការពារសិទ្ធិមនុស្ស។ ការជួបប្រជុំជាមួយតំណាងក្រុម ឬ តំណាងបុគ្គលក្តី ត្រូវរៀបចំឲ្យបានត្រឹមត្រូវ ដើម្បីពន្យល់ប្រាប់គាត់ពីផែនការសន្តិសុខសុវត្ថិភាព។

បែងចែកការទទួលខុសត្រូវ រៀបចំតាក់តែងផែនការ កំណត់កាលបរិច្ឆេទចុងក្រោយ ដើម្បីអនុវត្តផែនការសន្តិសុខសុវត្ថិភាពនោះ។

រក្សាទំនាក់ទំនងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឲ្យបានជាប់លាប់ ក្នុងការធ្វើផែនការ។

យកផែនការសន្តិសុខសុវត្ថិភាពនោះផ្សព្វផ្សាយដល់បុគ្គលិកអង្គការសង្គមស៊ីវិលគ្រប់រូបឲ្យបានដឹង។ យកល្អគួរតែធ្វើបទបង្ហាញផ្ទាល់ ដើម្បីគ្រប់គ្នា អាចជជែកពិភាក្សាពីសារៈសំខាន់នៃសន្តិសុខសុវត្ថិភាពនោះ។ ត្រូវប្រាកដថា បុគ្គលគ្រប់រូប នៅក្នុងអង្គការ ឯកភាពយល់ស្របលើខ្លឹមសារនៃផែនការនោះ។

ត្រូវប្រាកដថា មានអ្នកទទួលខុសត្រូវម្នាក់ តាមដានការអនុវត្ត និងពិនិត្យឡើងវិញ លើផែនការសន្តិខសុវត្ថិភាពនោះ។

## ២. តើនឹងត្រូវធ្វើអ្វីខ្លះ នៅពេលធ្វើការជាមួយសហគមន៍ ឬបណ្តាញមូលដ្ឋាន

រៀបចំកិច្ចប្រជុំមួយជាមួយសមាជិក ក្នុងសហគមន៍ ឬបណ្តាញមូលដ្ឋាន ដើម្បីពិភាក្សាអំពីលទ្ធភាពនៃការបង្កើតផែនការសន្តិសុខសុវត្ថិភាព។

លើកកម្ពស់ការយល់ដឹងអំពីសន្តិសុខសុវត្ថិភាព និងការប្តេជ្ញាចិត្តប្រកាន់ខ្ជាប់អនុវត្តតាមវិធានការនោះ។

ជំរុញនិងលើកទឹកចិត្តឲ្យអ្នករាល់គ្នាចូលរួមចំណែក។

បែងចែកការទទួលខុសត្រូវ ក្នុងរៀបចំតាក់តែងផែនការនោះ។

រក្សាទំនាក់ទំនងដល់គ្រប់សមាជិកសហគមន៍ បណ្តាញមូលដ្ឋានដែលមានការពាក់ព័ន្ធនៅក្នុងការរៀបចំបង្កើតផែនការនេះ។

ត្រូវប្រាកដថា មានអ្នកទទួលខុសត្រូវម្នាក់តាមដានការអនុវត្ត និងពិនិត្យឡើងវិញលើផែនការសន្តិសុខសុវត្ថិភាពនោះ។

ត្រូវប្រាកដថា ផែនការសន្តិសុខសុវត្ថិភាពនេះ អាចចែករំលែកបានតែនៅក្នុងសហគមន៍ ឬបណ្តាញមូលដ្ឋាន ប្រកបដោយការរក្សាការសម្ងាត់តែប៉ុណ្ណោះ។

## ៣. ការធ្វើពង្រាងផែនការ

ខ្លឹមសារនៃផែនការសន្តិសុខសុវត្ថិភាពនេះ អាចនឹងមានភាពខុសប្លែកគ្នា អាស្រ័យទៅតាមបរិបទរបស់អង្គការសង្គមស៊ីវិល និងសមាជិករបស់ខ្លួន តាមភាពងាយរងគ្រោះ និងកម្រិតសមត្ថភាពរបស់ពួកគេ ហានិភ័យដែលគេប្រឈម និងការគំរាមកំហែងដែលពួកគេទទួល។

ធ្វើផែនការឲ្យបានខ្លី ខ្លឹម មានភ្ជាប់ជាមួយឯកសារយោង ងាយស្រួលសម្រាប់អ្នកប្រើប្រាស់ និងដែលជាឯកសារបច្ចុប្បន្នភាព។

ផែនការនោះ ត្រូវតែប្រាកដប្រជា និងអាចអនុវត្តបាន ឧទា. ដូចជា មុនពេលចុះបំពេញបេសកកម្ម មិនត្រូវរៀបរាប់វែងឆ្ងាយពីអ្វីដែលត្រូវធ្វើនោះឡើយ។

ត្រូវរក្សាផែនការនោះ ទុកជាការសម្ងាត់។

# ៦. ការអនុវត្ត និងការពិនិត្យឡើងវិញលើផែនការសន្តិសុខសុវត្ថិភាព

## តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីអនុវត្តផែនការពីសន្តិសុខសុវត្ថិភាព

ផែនការសន្តិសុខសុវត្ថិភាព គួរអនុវត្តនៅកម្រិតចំនួន៣៖

- កម្រិតបុគ្គល៖ បុគ្គលម្នាក់ៗ ត្រូវអនុវត្តតាមផែនការនេះ ដើម្បីឲ្យការងារមានប្រសិទ្ធភាព។
- កម្រិតអង្គការ៖ អង្គការទាំងមូល ត្រូវអនុវត្តតាមផែនការនោះ។
- កម្រិតអន្តរអង្គការ៖ កិច្ចសហប្រតិបត្តិការរវាងអង្គការ និងអង្គការនានា ត្រូវតែបន្តឲ្យមានភាពល្អប្រសើរតាមធម្មតា ដើម្បីរក្សាសន្តិសុខសុវត្ថិភាព។

## តើនឹងត្រូវធ្វើអ្វីខ្លះ ដើម្បីពិនិត្យឡើងវិញលើផែនការសន្តិសុខសុវត្ថិភាព

ផែនការសន្តិសុខសុវត្ថិភាព គឺជាការងារដែលត្រូវធ្វើជាប្រចាំ។ គេគួរតែត្រួតពិនិត្យវាជាប្រចាំនៅពេលដែលមានហានិភ័យថ្មីណាមួយកើតឡើង ឬទទួលការគំរាមកំហែងណាមួយ ដើម្បីពិនិត្យមើលថាតើសកម្មភាពដែលបានរៀបចំក្នុងផែនការនោះ គ្រប់គ្រាន់ក្នុងការដោះស្រាយជាមួយនឹងហានិភ័យនោះបានដែរ ឬទេ។

ផែនការសន្តិសុខសុវត្ថិភាព គួរតែធ្វើការពិនិត្យឡើងវិញបន្ទាប់ពីមានឧបទ្ទវហេតុណាមួយកើតឡើង ដើម្បីពិនិត្យមើលថាតើអ្នករាល់គ្នាបានអនុវត្តតាមផែនការនោះដែរ ឬទេ។

ក្រោយពេលដែលមានការកែប្រែលើផែនការសន្តិសុខសុវត្ថិភាពនោះហើយ ឯកសារថ្មីត្រូវចុះកាលបរិច្ឆេទថ្ងៃខែឲ្យបានច្បាស់លាស់ ដើម្បីប្រាកដថា ផែនការមួយណាដែលធ្វើចុងក្រោយបង្អស់។ ត្រូវប្រាប់អ្នករាល់គ្នាបានដឹង អំពីឯកសារថ្មីនោះ។

ផែនការសន្តិសុខសុវត្ថិភាព គួរតែពិនិត្យឡើងវិញឲ្យបានទៀងទាត់រៀងរាល់ឆ្នាំ ទោះបីជាមានការកែប្រែតិចតួច ក្តី។

# IV.
# ឧទាហរណ៍

# បម្រាម

ឧទាហរណ៍ទាំងឡាយនេះ ត្រូវតែស្របតាមស្ថានភាព និងកាលៈទេសៈរបស់អ្នកការពារសិទ្ធិមនុស្ស ឬអង្គការសង្គមស៊ីវិលនីមួយៗ

## ១. តារាងឧទាហរណ៍ខាងក្រោមនេះ រៀបរាប់ពីហានិភ័យ ឬភាពងាយរងគ្រោះ ឬកម្រិតសមត្ថភាព តាមក្រុមអ្នកការពារសិទ្ធិមនុស្សនានា[១]

| ក្រុមគោលដៅ | វិស័យការងារ | ការគំរាមកំហែងដោយសារការងារ | ភាពងាយរងគ្រោះ ឬកម្រិតសមត្ថភាព |
|---|---|---|---|
| ក្រុមអ្នកសារព័ត៌មាន<br>ក្រុមសកម្មជន<br>ប្រព័ន្ធផ្សព្វផ្សាយ<br>ក្រុមអ្នកសរសេរប្លុក | ▸ ស៊ើបអង្កេត<br>▸ ចុះផ្សាយពីការរំលោភសិទ្ធិមនុស្សផ្សេងៗ | ▸ ការមាក់ងាយ (ស្និកម៉ា)<br>▸ ការចាប់ខ្លួន<br>▸ ការបិទ វិទ្យុ ឬកាសែត<br>▸ ការរឹតត្បឹតផ្នែកហិរញ្ញវត្ថុ | អ្នកការពារសិទ្ធិមនុស្សត្រូវបំពេញត្រង់ចំណុចនេះដោយខ្លួនឯង |
| សកម្មជនសហគមន៍ | ការស៊ើបអង្កេតពីការរំលោភសិទ្ធិមនុស្សផ្សេងៗទៅលើជនជាតិដើមភាគតិចនានា | ▸ ដោយការតាមឃ្លាំមើល<br>▸ ដោយការបំភិតបំភ័យ<br>▸ ដោយការមាក់ងាយ (ស្និកម៉ា)<br>▸ ដោយការយាយីរំខានតាមផ្លូវច្បាប់ និងតាមផ្លូវរដ្ឋបាល | អ្នកការពារសិទ្ធិមនុស្សត្រូវបំពេញត្រង់ចំណុចនេះដោយខ្លួនឯង |

១ ឧទាហរណ៍ដែលបានសម្របតាមសៀវភៅណែនាំអំពីការការពារសម្រាប់អ្នកការពារសិទ្ធិមនុស្ស បោះពុម្ពថ្មី ឆ្នាំ២០០៩ ទំព័រ ២០២-២០៤ របស់ អង្គការអ្នកការពារអន្តរជាតិ

| | | | |
|---|---|---|---|
| សកម្មជនដីធ្លី | ▸ សិទ្ធិដីធ្លី<br>▸ ការទាមទារ និង ការសើរើពីដីធ្លី<br>▸ ការដាក់ញត្តិផ្សេងៗ | ▸ ដោយការតាមឃ្លាំមើល<br>▸ ដោយការបំភិតបំភ័យ<br>▸ ដោយការមាក់ងាយ (ស្ទិកម៉ា)<br>▸ ដោយការយាយីរំខានតាមផ្លូវច្បាប់ និងតាមផ្លូវរដ្ឋបាល | អ្នកការពារសិទ្ធិមនុស្សត្រូវបំពេញត្រង់ចំណុចនេះដោយខ្លួនឯង |
| សមាជិកសហជីព | ▸ សិទ្ធិមនុស្ស និង ការងារ | ▸ ដោយការតាមឃ្លាំមើល<br>▸ ដោយការបំភិតបំភ័យ<br>▸ ដោយការមាក់ងាយ (ស្ទិកម៉ា)<br>▸ ដោយការយាយីរំខានតាមផ្លូវច្បាប់ និងតាមផ្លូវរដ្ឋបាល | អ្នកការពារសិទ្ធិមនុស្សត្រូវបំពេញត្រង់ចំណុចនេះដោយខ្លួនឯង |
| មេធាវី | ▸ ការការពារសំណុំរឿងសិទ្ធិមនុស្ស<br>▸ ការតស៊ូប្រឆាំងនឹងនិទណ្ឌភាព និង ការចូលរួមសង្កេតមើលការជំនុំជម្រះក្តី<br>▸ ការចូលរួមប្រឹក្សាយោបល់ផ្នែកច្បាប់ និងនយោបាយ<br>▸ ការរិះគន់ជាសាធារណៈអំពីការរំលោភសិទ្ធិមនុស្សផ្សេងៗ | ▸ ដោយការបំភិតបំភ័យ<br>▸ ដោយការយាយីរំខានតាមផ្លូវច្បាប់ និងតាមផ្លូវរដ្ឋបាល | អ្នកការពារសិទ្ធិមនុស្សត្រូវបំពេញត្រង់ចំណុចនេះដោយខ្លួនឯង |

# ២. ឧទាហរណ៍នៃការត្រួតពិនិត្យពីសន្តិសុខសុវត្ថិភាព ផ្ទាល់ខ្លួន[២]

| ឧទាហរណ៍ពីផ្នែកនីមួយៗ អំពីភាពងាយរងគ្រោះ និងពីកម្រិតសមត្ថភាព | ឧទាហរណ៍ស្តីពីតម្រូវការព័ត៌មាន ដើម្បីវាយតំលៃ ភាពងាយរងគ្រោះ ឬកម្រិតសមត្ថភាពផ្សេងៗ |
|---|---|
| **ទិដ្ឋភាពភូមិសាស្ត្រ បច្ចេកទេស និងរូបវ័ន្ត** | **ទិដ្ឋភាពភូមិសាស្ត្រ បច្ចេកទេស និងរូបវ័ន្ត** |
| ការបង្ហាញខ្លួនដោយចំហរ | តើអ្នកត្រូវចូលទៅធ្វើការក្នុងតំបន់គ្រោះថ្នាក់នោះ ឬគ្រាន់តែធ្វើដំណើរឆ្លងកាត់ម្តងម្កាល ដើម្បីបំពេញសកម្មភាពការងារប្រចាំថ្ងៃ ?<br>តើតំបន់អ្នករស់នៅ និងកន្លែងអ្នកធ្វើការ មានសុវត្ថិភាពដែរ ឬទេ ? |
| លំនៅដ្ឋាន | តើផ្ទះរបស់អ្នកមានសុវត្ថិភាពដែរ ឬទេ ?<br>តើផ្ទះរបស់អ្នកមានលក្ខណៈដូចម្តេចខ្លះ ឧទា. ដូចជា ទ្វារ បង្អួច ភ្លើងបំភ្លឺពេលយប់... ? |
| ការិយាល័យធ្វើការ | តើការិយាល័យអ្នក បើកទ្វារទទួលសាធារណៈជនទូទៅដែរ ឬទេ ?<br>តើមានកន្លែងសម្រាប់តែបុគ្គលិកចេញចូល ដែរ ឬទេ ? |
| មធ្យោបាយធ្វើដំណើរ | តើការធ្វើដំណើរ ឬការប្រើប្រាស់មធ្យោបាយធ្វើដំណើរ ប្រកបដោយសុវត្ថិភាពដែរឬទេ (មធ្យោបាយឯកជន ឬ សាធារណៈ) ? តើអ្នកអាចទទួលបានកន្លែងស្នាក់នៅ ដែលមានសុវត្ថិភាព នៅពេលអ្នកធ្វើដំណើរដែរ ឬទេ ? |

២ អ្នកការពារសិទ្ធិមនុស្សជួរមុខ សៀវភៅណែនាំអំពីការការពារសម្រាប់អ្នកការពារសិទ្ធិមនុស្ស ឆ្នាំ២០០៥ ទំព័រ ២៤-២៧។

| | |
|---|---|
| ការទំនាក់ទំនង | តើអ្នកមានមធ្យោបាយទាក់ទងគ្នាល្អ ដែរឬទេ ជាពិសេស ការប្រើប្រាស់ទូរស័ព្ទដៃ ?<br>តើវាងាយស្រួលទាក់ទងគ្នា ដែរ ឬទេ ?<br>តើការទំនាក់ទំនងនោះ ដំណើរការបានល្អគ្រប់ពេលវេលាដែរ ឬទេ ?<br>តើគេអាចលួចបានដែរឬទេ ? |
| **ការគ្រប់គ្រងព័ត៌មាន** | **ការគ្រប់គ្រងព័ត៌មាន** |
| ការរក្សា ការបញ្ជូន និងការទទួលព័ត៌មាន | តើអ្នកអាចរក្សាទុកព័ត៌មាននៅកន្លែងដែលមានសុវត្ថិភាព និងជឿទុកចិត្តបានដែរ ឬទេ ? តើគេអាចលួចបានដែរឬទេ ?<br>តើព័ត៌មានអាចការពារពីវីរុស និងអ្នកលួចចូលមើល (Hacker) បានដែរ ឬទេ ?<br>តើអ្នកអាចបញ្ជូន និងទទួលព័ត៌មានបានដោយសុវត្ថិភាព ដែរឬទេ ? |
| ការគ្រប់គ្រងព័ត៌មានតាមឌីជីថល | តើអ្នកទុកកុំព្យូទ័ររបស់អ្នកដោយសុវត្ថិភាពដែរ ឬទេ ?<br>តើអ្នកមានដាក់ពាក្យសម្ងាត់ (Password) រឹងមាំដែរឬទេ ?<br>តើអ្នកមានប្រើកូដ សម្រាប់ព័ត៌មានណាដែលរសើបដែរឬទេ ? តើអ្នកបានត្រៀមខ្លួន នៅពេលដែលបាត់កុំព្យូទ័ររបស់អ្នកដែរឬទេ ?<br>តើអ្នកមានរក្សាទុក (backup) ព័ត៌មានទាំងអស់របស់អ្នក នៅកន្លែងដោយឡែកមួយផ្សេងដែរឬទេ ? តើអ្នកមានបំផ្លាញចោលព័ត៌មានដែលអ្នកឈប់ប្រើវាដែរ ឬទេ ?<br>តើអ្នកដឹងអំពីរបៀបប្រើប្រាស់ ឬបញ្ជូនព័ត៌មានសម្ងាត់ដែរ ឬទេ ? |
| **វិស័យរចនាសម្ព័ន្ធ** | **វិស័យរចនាសម្ព័ន្ធ** |
| រចនាសម្ព័ន្ធរបស់ស្ថាប័ន ឬ អង្គការ | តើការងារសំខាន់ៗមានចាត់មនុស្សម្នាក់ ឬច្រើននាក់ទទួលខុសត្រូវដែរ ឬទេ ?<br>តើការសម្រេចចិត្តនោះ ធ្វើឡើងដោយរបៀបណា ?<br>តើការចូលរួមក្នុងចំណោមបុគ្គលិក មានត្រឹមកម្រិតណា ?<br>តើព័ត៌មាននោះ ផ្សព្វផ្សាយដោយរបៀបណា ?<br>ប្រសិនបើមានរឿងអ្វីមួយកើតឡើងទៅលើបុគ្គលណាម្នាក់ ដែលជាអ្នកធ្វើការសម្រេចចិត្ត<br>តើមានត្រៀមបុគ្គលណាមួយជំនួសដែរ ឬទេ ? |

| | |
|---|---|
| ផែនការសន្តិសុខនិង នីតិវិធីសន្តិសុខសុវត្ថិភាព | តើមានបានបង្កើតវិធាន និងនីតិវិធីផ្សេងៗសម្រាប់សន្តិសុខ សុវត្ថិភាព រួចជាស្រេចហើយ ឬនៅ?<br>តើអ្នករាល់គ្នាបានយល់ជ្រួតជ្រាបអំពីវិធានទាំងអស់នេះដែរ ឬទេ?<br>តើអ្នករាល់គ្នាព្រមអនុវត្តតាមវិធានសន្តិសុខសុវត្ថិភាពទាំងអស់នោះដែរ ឬទេ? |
| ការជ្រើសរើសបុគ្គលិក និង ការទទួលភ្ញៀវ | តើអ្នកមាននីតិវិធីជាក់លាក់ នៅក្នុងការជ្រើសរើសបុគ្គលិកដែរឬទេ?<br>តើអ្នកមាននីតិវិធីដូចម្ដេចខ្លះ តម្រូវពីសន្តិសុខសុវត្ថិភាព សម្រាប់អ្នកស្ម័គ្រចិត្តហាត់ការម្ដងម្កាល ដល់អង្គការ របស់អ្នក?<br>តើអ្នកទទួលភ្ញៀវចេញ ឬចូលដោយរបៀបណា?<br>តើមានការត្រួតពិនិត្យភ្ញៀវចេញ ឬចូលការិយាល័យរបស់អ្នកដែរ ឬទេ?<br>តើភ្ញៀវចេញ ឬចូលនោះ មានតម្រូវឲ្យចុះឈ្មោះដែរ ឬទេ? |
| ការថែទាំ និងយកចិត្តទុកដាក់ដល់ជនរងគ្រោះ ឬសាក្សី ដែលអ្នកធ្វើការជាមួយ | តើអ្នកបានវាយតម្លៃពីហានិភ័យរបស់សាក្សី និងជនរងគ្រោះដែរ ឬទេ នៅពេលដែលអ្នកកំពុងធ្វើការលើករណីរបស់ពួកគេ?<br>តើអ្នកមានបានគិតពីវិធានការសន្តិសុខសុវត្ថិភាពរបស់ពួកគេដែរឬទេ នៅពេលដែលអ្នកទៅជួបពួកគេ? |
| ធនធានសម្រាប់បម្រើការងារ | តើអ្នកមានព័ត៌មានគ្រប់គ្រាន់ច្បាស់លាស់ អំពីបរិស្ថានជុំវិញការងាររបស់អ្នកដែរ ឬទេ?<br>តើអ្នកយល់ច្បាស់អំពីការគំរាមកំហែង ភាពងាយរងគ្រោះ និងផលប៉ះពាល់កម្រិតណា? |
| ធ្វើការជាដៃគូ | តើអ្នកអាចរកដៃគូល្អជាក់លាក់ ដែលអាចជួយបង្កើនកម្រិតសមត្ថភាពការពារដល់អ្នកបានដែរ ឬទេ? |
| កម្រិតសមត្ថភាពក្នុងការកៀងគរមនុស្ស | តើអ្នកអាចមានលទ្ធភាពកៀងគរមនុស្ស ដើម្បីធ្វើសកម្មភាពជាសាធារណៈដែរ ឬទេ? |
| ធនធានហិរញ្ញវត្ថុ | តើអ្នកមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ពេលមានបញ្ហាទាក់ទងនឹងសន្តិសុខសុវត្ថិភាពដែរ ឬទេ? |

| | |
|---|---|
| ទំនាក់ទំនងបណ្តាញថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ | តើអ្នកមានទំនាក់ទំនងនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិដែរ ឬទេ ?<br>តើអ្នកអាចចេញជាសេចក្តីប្រកាសបន្ទាន់ណាមួយ ប្រាប់ដល់ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ បានដែរ ឬទេ ប្រសិនបើអ្នកត្រូវការចាំបាច់ ? |
| ទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន | តើអ្នកអាចទាក់ទងជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានថ្នាក់ជាតិ និងអន្តរជាតិបានដែរ ឬទេ ?<br>តើអ្នកចេះប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីយកប្រយោជន៍ពីប្រព័ន្ធនោះដែរ ឬទេ ? |
| **ផ្នែកចិត្តវិទ្យា** | **ផ្នែកចិត្តវិទ្យា** |
| កម្រិតសមត្ថភាពនៅក្នុងការគ្រប់គ្រងភាពតានតឹងក្នុងអារម្មណ៍ និងភាពភ័យខ្លាច | តើអ្នកដោះស្រាយភាពតានតឹងក្នុងអារម្មណ៍ដោយរបៀបណាដែរ ?<br>តើបុគ្គលិកគ្រប់រូបនៅក្នុងអង្គការ អាចបញ្ចេញនូវអារម្មណ៍តានតឹង ឬភាពភ័យខ្លាចរបស់ខ្លួនបានដែរ ឬទេ ?<br>តើការយល់ដឹង និងសាមគ្គីភាពក្នុងអង្គការ មានកម្រិតណា ?<br>តើមានបុគ្គលិកណាខ្លះ សម្តែង ឬបង្ហាញពីភាពអស់សង្ឃឹមដែរ ឬទេ ? |

# ៣. ឧទាហរណ៍ខាងក្រោមនេះ រៀបរាប់ពីការវិភាគលើការគំរាមកំហែងផ្ទាល់ខ្លួន[៣]

តើអ្នកធ្លាប់ទទួលការការគំរាមកំហែងដែរឬទេ ? ប្រសិនបើធ្លាប់មាន សូមចំណាយពេលអានជំហានទាំង៥ នៃការវិភាគអំពីការគំរាមកំហែង ដូចខាងក្រោមនេះ។

១. តើមានកត្តាអ្វីខ្លះ ដែលកើតឡើងជុំវិញពីការគំរាមកំហែងនោះ ?

..........................................................................................................................

២. តើធ្លាប់មានការគំរាមកំហែងនេះពីមុនមកញយៗដែរឬទេ ?

..........................................................................................................................

៣. តើការគំរាមកំហែងនោះ មានគោលដៅយ៉ាងដូចម្ដេចខ្លះ ?

..........................................................................................................................

៤. តើអ្នកដឹងថា អ្នកណាជាជនបង្កដល់ការគំរាមកំហែងនោះ ?

..........................................................................................................................

៥. ចុងក្រោយ បន្ទាប់ពីវិភាគសំណួរខាងលើនេះហើយ តើអ្នកគិតថា ការគំរាមកំហែងនោះ វានឹងស្ដែងអាចចេញជាសកម្មភាពជាក់ស្ដែងដែរ ឬទេ ?

..........................................................................................................................

៦. តាមការយល់ឃើញរបស់អ្នកផ្ទាល់ពីកម្រិតប្រឈមនឹងភាពងាយរងគ្រោះ តើអ្នកនឹងចាត់វិធានការយ៉ាងដូចម្ដេចខ្លះ ?

..........................................................................................................................

៣ អ្នកការពារសិទ្ធិមនុស្សជួរមុខ សិក្ខាសាលាស្ដីពីសន្តិសុខ៖ ជំហានក្នុងការអនុវត្តជាក់ស្ដែង សម្រាប់អ្នកការពារសិទ្ធិមនុស្សដែលស្ថិតក្នុងហានិភ័យ ឆ្នាំ២០១១ ទំព័រ ៣០-៣២។

# ៤. ឧទាហរណ៍ខាងក្រោមនេះ គឺជាផែនការការពារសុវត្ថិភាពផ្ទាល់ខ្លួន[៤]

## ការណែនាំជាទូទៅ

**ហានិភ័យ ១៖** ....................................................................................................

ការវាយតម្លៃពីការគំរាមកំហែង៖: .................................................................................

ភាពងាយរងគ្រោះផ្សេងៗ៖ ...........................................................................................

កម្រិតសមត្ថភាព៖ ......................................................................................................

ផែនការសកម្មភាព៖

១. .............................................................................

២. .............................................................................

៣. .............................................................................

៤. .............................................................................

៥. .............................................................................

**ហានិភ័យ ២៖** ..................................................................................................

ការវាយតម្លៃពីការគំរាមកំហែង៖: .................................................................................

ភាពងាយរងគ្រោះផ្សេងៗ៖ ...........................................................................................

កម្រិតសមត្ថភាព៖ ......................................................................................................

**ផែនការសកម្មភាព៖**

១. .............................................................................

២. .............................................................................

៣. .............................................................................

៤. .............................................................................

៥. .............................................................................

៤ អ្នកការពារសិទ្ធិមនុស្សជួរមុខ សិក្ខាសាលាស្តីពីសន្តិសុខ៖ ជំហានក្នុងការអនុវត្តជាក់ស្តែង សម្រាប់អ្នកការពារសិទ្ធិមនុស្សដែលស្ថិតក្នុងហានិភ័យ ឆ្នាំ២០១១ ទំព័រ ៥១ និង ៥២។

**ឧទាហរណ៍**[៥]

| | |
|---|---|
| **ហានិភ័យ ១៖** | **ការចាប់ខ្លួនក្នុងករណី មន្ត្រីនគរបាលឆែកឆេរលំនៅដ្ឋាន និងការរឹបអូសយកឯកសារ ទូរស័ព្ទ កុំព្យូទ័រយួរដៃ ។ល។** |
| **ការវាយតម្លៃពីការគំរាមកំហែង៖** | តាមធម្មតា នគរបាល ច្រើនតែឆ្មក់ចូលឆែកឆេរលំនៅដ្ឋាននាពេលព្រឹកព្រលឹម។ |
| **ភាពងាយរងគ្រោះ ៖** | យើងត្រូវដឹងថាអង្គការយើងមានព័ត៌មានរសើបច្រើន ដូច្នេះការឆែកឆេរពុំមានដីកា និងពុំមានវត្តមានមេធាវីទៀតផងនោះ បែបនេះ ធ្វើឲ្យមានអារម្មណ៍ទទួលរងការគាបសង្កត់ ដោយហេតុថា ការអនុវត្តនោះគ្មាននីតិវិធីត្រឹមត្រូវ ។ |
| **កម្រិតសមត្ថភាព៖** | លទ្ធភាពធ្វើផែនការ (រិះរកគំនិតល្អៗគិតទុកជាមុន ពីរបៀបដែលនឹងត្រូវឆ្លើយតប ការនេះវានឹងអាចជួយកាត់បន្ថយអន្តរាយផ្សេងៗដែលអាចកើតមាន)។ |

**ផែនការសកម្មភាព៖**

១. ពិភាក្សាអំពីហានិភ័យជាមួយគ្រួសារ ប្រាប់គេថា តើត្រូវទូរស័ព្ទទៅកាន់អ្នកណាមុនគេ ប្រសិនបើមន្ត្រីនគរបាលមកដល់លំនៅដ្ឋានរបស់យើង បើអាចត្រូវទាក់ទងរកសហការី ឬមិត្តភក្តិ ដើម្បីធ្វើជាសាក្សីនៅពេលមានការឆែកឆេរលំនៅដ្ឋាន ប្រសិនបើវត្តមានរបស់ពួកគេ នឹងមិនត្រូវទទួលនូវរងហានិភ័យនៃការចាប់ខ្លួនដែរទេនោះ ហើយតើត្រូវទូរស័ព្ទទៅកាន់អ្នកណាបន្ទាប់ទៀតនោះ ដូចជា អង្គការសិទ្ធិមនុស្សដទៃទៀត។

២. ត្រូវរៀបចំទុកដាក់ក្មេងៗឲ្យគេងផ្ទះណាមួយផ្សេងទៀត ចំនួនពីរឬបីថ្ងៃ ក្នុងពេលហានិភ័យមានកម្រិតខ្ពស់។

៣. កក់ត្រារាល់ឧបទ្ទវហេតុ។

៤. ត្រូវដឹងអំពីសិទ្ធិរបស់ខ្លួនពេលមានការឃុំខ្លួន ដើម្បីឲ្យគេដឹងថាខ្លួនមានសិទ្ធិស្នើសុំដែរ (បើទោះបីជា សិទ្ធិទាំងនោះ មិនត្រូវបានគេផ្តល់ឲ្យយ៉ាងណាក៏ដោយ)។

៥. ក្នុងករណីដែលគេអនុញ្ញាតឲ្យមេធាវីចូលជួប តើមេធាវីមានបានប្រាប់អំពីសិទ្ធិរបស់អ្នកដែរឬទេ។

៦. ព័ត៌មានរសើបពីការងារ មិនត្រូវយកទៅទុកនៅផ្ទះឡើយ។

៧. ត្រូវលុបព័ត៌មានរសើបទាំងអស់ចេញពីកុំព្យូទ័រ និងទូរស័ព្ទដៃរបស់អ្នក។

៨. ត្រូវប្រាកដថា រាល់ការងារផ្ទាល់ខ្លួនទាំងអស់របស់យើង មានដូចជា ក្រដាសពន្ធផ្សេងៗ ត្រូវទុកដាក់ឲ្យបានត្រឹមត្រូវ ដើម្បីកុំឲ្យគេយកធ្វើជាលេស សម្រាប់ធ្វើការចោទប្រកាន់ៗ។

៥ អ្នកការពារសិទ្ធិមនុស្សជួបមុខ សិក្ខាសាលាស្តីពីសន្តិសុខ៖ ជំហានក្នុងការអនុវត្តជាក់ស្តែង សម្រាប់អ្នកការពារសិទ្ធិមនុស្សដែលស្ថិតក្នុងហានិភ័យ ឆ្នាំ២០១១ ទំព័រ ៥១ និង ៥៣។

# 5. ឧទាហរណ៍ខាងក្រោមនេះ គឺជាកម្រងបញ្ជីត្រួតពិនិត្យ (checklist) ដែលអ្នកការពារសិទ្ធិមនុស្សកំណត់ពីកម្រិតសមត្ថភាពរបស់ខ្លួន[៦]

## ១. ការយល់ដឹងអំពី ៖

- ហានិភ័យ និងការគំរាមកំហែងដែលប្រឈម។
- សិទ្ធិស្របច្បាប់របស់អ្នក មានចែងក្នុងច្បាប់ជាតិ យន្តការដោះស្រាយនៅថ្នាក់ជាតិ និងនៅថ្នាក់អន្តរជាតិ ។
- សហគមន៍ វប្បធម៌ និងប្រព័ន្ធនយោបាយរបស់ប្រទេសអ្នក។
- របៀបដោះស្រាយភាពតានតឹងក្នុងអារម្មណ៍របស់អ្នក។

## ២. ការប្រាស្រ័យទាក់ទង៖

- សហគមន៍មូលដ្ឋានដែលគាំទ្រនិងអាចពឹងពាក់បាន។
- កម្រិតសមត្ថភាពដែលអាចកៀងគរមនុស្សច្រើនបានតែក្នុងរយៈពេលខ្លី។
- ទំនាក់ទំនងតាមមូលដ្ឋាន មានដូចជា អង្គការសិទ្ធិមនុស្ស ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងបុគ្គលដែលមានឥទ្ធិពលនានា។
- ទំនាក់ទំនងនៅក្នុងជួររដ្ឋាភិបាល ដូចជា នគរបាល និងតួអង្គសំខាន់ៗផ្សេងទៀត។
- ទំនាក់ទំនងតាមស្ថានទូតនានា ដែលមានគោលការណ៍ណែនាំជាក់លាក់ អំពីការការពារអ្នកការពារសិទ្ធិមនុស្ស។
- ទំនាក់ទំនងបណ្ដាញអង្គការសិទ្ធិមនុស្សថ្នាក់តំបន់ និងថ្នាក់អន្តរជាតិនានា។

៦ អ្នកការពារសិទ្ធិមនុស្សជួរមុខ សិក្ខាសាលាស្តីពីសន្តិសុខ៖ ជំហានជាក់ស្តែងសម្រាប់អ្នកការពារសិទ្ធិមនុស្សដែលស្ថិតក្នុងហានីភ័យ ឆ្នាំ២០១១ ទំព័រ ៥១ និង ៧២។
សម្រាប់បញ្ជីត្រួតពិនិត្យបន្ថែមទៀត សូមមើល អ្នកការពារសិទ្ធិមនុស្សជួរមុខ ឧបសម្ព័ន្ធ ៤ ដល់ ១៥ នៃសៀវភៅការងារស្តីពីសន្តិសុខ៖ ជំហានក្នុងការអនុវត្តជាក់ស្តែង សម្រាប់អ្នកការពារសិទ្ធិមនុស្សដែលស្ថិតក្នុងហានិភ័យ និងសៀវភៅណែនាំអំពីការការពារសម្រាប់អ្នកការពារសិទ្ធិមនុស្ស ទំព័រទី ៧៥ ៨១ និង ៨៣។

## ៣. ការធ្វើផែនការ

- ផែនការពីសន្តិសុខសុវត្ថិភាពអំពីហានិភ័យ ជារៀងរាល់ថ្ងៃ។
- រៀបចំផែនការបំរុងទុកក្នុងករណីដែលមានហានិភ័យអាក្រក់កើតឡើង។
- រៀបចំផែនការសម្រាប់ក្នុងគ្រាអាសន្ន (នៅពេលមានហានិភ័យដែលមិនបានរំពឹងទុក កើតឡើង)។
- មានអ្នកទទួលខុសត្រូវច្បាស់លាស់ សម្រាប់បញ្ហាសន្តិសុខសុវត្ថិភាព។
- ពិនិត្យឡើងវិញជាទៀងទាត់ ទៅលើផែនការសន្តិសុខសុវត្ថិភាព។

## ៤. អង្គការ ឬការិយាល័យ៖

- សាធារណៈជនទទួលស្គាល់ថាមានកេរ្តិ៍ឈ្មោះល្អ។
- មានសន្តិសុខសុវត្ថិភាពភាពរឹងមាំ ឧទា. ដូចជា ទ្វាររបង មេសោរ ទ្វារ និងបង្អួចគត់មត់ ទ្វដែក និងមានបំពាក់ភ្លើងបំភ្លឺបានល្អ។ល។
- មានអាណត្តិការងារច្បាស់លាស់។
- មានបរិយាកាសអំណោយផលដែលគាំទ្រដល់ការពិភាក្សាអំពីហានិភ័យផ្សេងៗ។
- សុវត្ថិភាពផ្នែកព័ត៌មានវិទ្យា (IT)។
- មានប្រព័ន្ធច្បាស់លាស់ សម្រាប់ដោះស្រាយព័ត៌មានរសើប។
- មានគោលនយោបាយច្បាស់លាស់សម្រាប់ភ្ញៀវចេញចូល។

## ៥. ផ្នែកផ្សេងៗ៖

- អាកប្បកិរិយាផ្ទាល់ខ្លួន ប្រកាន់ខ្ជាប់ការគោរពច្បាប់។
- មានការគាំទ្រ និងលើកទឹកចិត្តពីក្រុមគ្រួសារ។
- អាចចេញចូលផ្ទះសុវត្ថិភាពបាន ប្រសិនបើមានការចំបាច់។
- មធ្យោបាយធ្វើដំណើរមានសុវត្ថិភាព។
- មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់។
- មានប័ណ្ណធានារ៉ាប់រងផ្នែកសុខភាព។
- មានសមត្ថភាពគ្រប់គ្រងភាពតានតឹងក្នុងអារម្មណ៍។

# V.

# សៀវភៅណែនាំទូទៅ ស្តីពី សន្តិសុខសុវត្ថិភាពសម្រាប់ អ្នកការពារសិទ្ធិមនុស្ស

## ១. រដ្ឋ និងអង្គការថ្នាក់តំបន់នានា

- OSCE/ODIHR, គោលការណ៍ណែនាំស្តីពី ការការពារអ្នកការពារសិទ្ធិមនុស្ស ឆ្នាំ២០១៤។
- ការការពារ និងការគាំទ្រអ្នកការពារសិទ្ធិមនុស្ស។ គោលការណ៍ណែនាំជាសាធារណៈ របស់ក្រសួងការបរទេសនៃប្រទេសហូឡង់ ស្តីពីការអនុវត្តគោលការណ៍ណែនាំ របស់សហភាពអឺរ៉ុប ស្តីពីការអ្នកការពារសិទ្ធិមនុស្ស ប្រទេសហូឡង់ ឆ្នាំ២០១៤។
- គោលការណ៍ណែនាំ របស់ប្រទេសស្វីសស្តីពីការការពារអ្នកការពារសិទ្ធិមនុស្ស ប្រទេសស្វីស ឆ្នាំ២០១៣។
- សំឡេងក្នុងហានិភ័យ៖ គោលការណ៍ណែនាំរបស់ប្រទេសកាណាដា ស្តីពីការគាំទ្រ អ្នកការពារសិទ្ធិមនុស្ស ប្រទេសកាណាដា។

## ២. ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR)

- កម្រងឯកសារសម្រាប់អ្នកការពារសិទ្ធិមនុស្សរបស់ប្រទេសនេប៉ាល់ ឆ្នាំ២០១១។
- អ្នកការពារសិទ្ធិមនុស្ស៖ ការការពារសិទ្ធិ ដើម្បីការពារសិទ្ធិមនុស្ស សាលកបត្រ ព័ត៌មាន លេខ២៩
- សិទ្ធិរបស់អ្នក ប្រសិនបើត្រូវបានមន្ត្រីនគរបាលឃុំខ្លួន ឆ្នាំ២០១៣។

# ៣. អង្គការសង្គមស៊ីវិលអន្តរជាតិ

## ១. អ្នកការពារជួរមុខ

- សៀវភៅណែនាំអំពីអង្គការអ្នកការពារជួរមុខ សម្រាប់អ្នកការពារសិទ្ធិមនុស្ស ឆ្នាំ២០០៥។
- សុវត្ថិភាពទាំងស្រុង៖ សៀវភៅណែនាំអំពីយុទ្ធសាស្ត្រសម្រាប់អ្នកការពារសិទ្ធិមនុស្ស។
- សៀវភៅណែនាំអំពីការការពារ សម្រាប់អ្នកការពារសិទ្ធិមនុស្ស ឆ្នាំ២០០៧។
- សៀវភៅស្តីពីសន្តិសុខសុវត្ថិភាព៖ ជំហានក្នុងការអនុវត្តជាក់ស្តែង សម្រាប់អ្នកការពារសិទ្ធិមនុស្សដែលស្ថិតក្នុងហានិភ័យ ឆ្នាំ២០១១ ។
- វេទិកាទីក្រុងឌុប្លីន ឆ្នាំ២០១៧ ស្តីពីអ្នកការពារសិទ្ធិមនុស្ស ដែលស្ថិតក្នុងហានិភ័យ។
- គោលការណ៍ណែនាំរបស់សហភាពអឺរ៉ុប ស្តីពីអ្នកការពារសិទ្ធិមនុស្ស និងសៀវភៅស្តីពីអ្នកការពារសិទ្ធិមនុស្សជួរមុខ។ តើបេសកកម្មការទូតសហភាពអឺរ៉ុប និងប្រទេសណ័រវេស អាចផ្តល់កិច្ចការពារបានអ្វីខ្លះ ? ឆ្នាំ២០០៧។
- សុវត្ថិភាពនៅក្នុងប្រអប់ "A"។ ឧបករណ៍ និងបច្ចេកទេសខាងសុវត្ថិភាពឌីជីថល https://securityinabox.org

## ២. កិច្ចការពារជាអន្តរជាតិ

- សៀវភៅណែនាំថ្មី ស្តីពីការអង្គការអ្នកការពារអន្តរជាតិសម្រាប់អ្នកការពារសិទ្ធិមនុស្ស ឆ្នាំ២០០៩។
- អ្នកការពារសិទ្ធិមនុស្សដែលស្ថិតក្នុងកម្រិតហានិភ័យខ្ពស់ ឆ្នាំ២០១៤។
- ការពារជីវិតអ្នក ជីវិតខ្ញុំ ជីវិតរបស់យើង។ មគ្គុទេសក៍សម្រាប់ស្ត្រីអ្នកការពារសិទ្ធិមនុស្ស របស់ប្រទេសកេនយ៉ា ឆ្នាំ២០១៤។
- មគ្គុទេសក៏សម្រាប់អ្នកសម្របសម្រួល សម្រាប់សៀវភៅណែនាំថ្មីស្តីពីការការពារសម្រាប់អ្នកការពារសិទ្ធិមនុស្ស។
- ការចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើអ្នកការពារសិទ្ធិមនុស្ស។ ការធ្វើចំណាត់ថ្នាក់បញ្ហា និងវិធានការក្នុងការឆ្លើយតប ឆ្នាំ២០១៥។
- ក្រោកឡើង! មគ្គុទេសក៍អំពីសុវត្ថិភាពសម្រាប់អ្នកការពារសិទ្ធិមនុស្សក្នុងទ្វីបអាហ្វ្រិក, ២០១៧

## ៣. ការពារអ្នកការពារ

- សៀវភៅទី II៖ សន្តិសុខអង្គការការពារអ្នកការពារសិទ្ធិមនុស្ស សុវត្ថិភាពផ្នែកឌីជីថល

# ៤. អង្គការសង្គមស៊ីវិលកម្ពុជា

## ១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

- ការការពារអ្នកការពារ៖ សន្តិសុខសុវត្ថិភាពសម្រាប់អ្នកការពារសិទ្ធិមនុស្ស មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងមាត្រា១៩ ឆ្នាំ២០១៣
- កម្រងឯកសារសម្រាប់អ្នកការពារសិទ្ធិមនុស្សក្នុងគ្រាអាសន្ន ឆ្នាំ២០១៧ ។
- គម្រោងអ្នកការពារសិទ្ធិមនុស្ស ឆ្នាំ២០១៨។

## ២. អង្គការសមធម៌កម្ពុជា (EC)

- មគ្គុទេសក៍អំពីសុវត្ថិភាពផ្ទាល់ខ្លួនសម្រាប់អ្នកការពារសិទ្ធិមនុស្ស។ ឯកសារសម្រាប់អ្នកសម្របសម្រួល បោះពុម្ពផ្សាយ ឆ្នាំ២០១០។

# VI.

# អង្គការនានាដែលជួយគាំទ្រ ដល់អ្នកការពារសិទ្ធិមនុស្ស

# ១. អង្គការសង្គមស៊ីវិលនៅកម្ពុជា

## ១. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ( CCHR )

មានគម្រោងសម្រាប់ការពារសិទ្ធិមនុស្ស ធ្វើការតាមឃ្លាំមើលពីស្ថានភាពអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីស្ថានភាពរបស់ពួកគេ។

ទូរស័ព្ទ៖ + 855 ( 0 )17 50 50 50 ( Hotline )

អ៊ីមែល៖ info@cchrcambodia.org

គេហទំព័រ៖ https://cchrcambodia.org

## ២. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា ( ADHOC )

ទូរស័ព្ទ៖ + 855 (0) 23 218-653 / 210-518 / 990-544

អ៊ីមែល៖ info@adhoccambodia.org

គេហទំព័រ៖ https://adhoccambodia.org

## ៣. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ ( LICADHO )

ទូរស័ព្ទ៖ + 855 (0)23 727 102 or (0) 23 216 602

អ៊ីមែល៖ contact@licadho-cambodia.org

គេហទំព័រ៖ www.licadho-cambodia.org

# ២. អង្គការសង្គមស៊ីវិលអន្តរជាតិ

## ១. វេទិកាអាស៊ី សម្រាប់ការអភិវឌ្ឍន៍សិទ្ធិមនុស្ស Forum-Asia

អង្គការ Forum-Asia គឺជាអង្គការដែលកម្មវិធីការងារអ្នកការពារសិទ្ធិមនុស្ស សំដៅដល់ការសម្រួលធ្វើឲ្យមានបរិយាកាសការងារកាន់តែល្អប្រសើរសម្រាប់អ្នកការពារសិទ្ធិមនុស្ស តាមរយៈការកាត់បន្ថយការគំរាមកំហែង ដែលកើតចេញមកពីសកម្មភាពការងាររបស់ពួកគេ។

អង្គការ Forum-Asia គឺជាសមាជិកយន្តការសហភាពអឺរ៉ុប ProtectDefenders.eu.

ទូរស័ព្ទ៖ + 66 2 108 264 345, Ext: ( 208 / 209 )

អ៊ីមែល៖ hrd@forum-asia.org

protection@forum-asia.org (for emergency assistance )

គេហទំព័រ៖ www.forum-asia.org

## ២. អង្គការអ្នកការពារអន្តរជាតិ ( Protection International )

អង្គការអ្នកការពារអន្តរជាតិ ( Protection International ) មានមូលនិធិគាំទ្រដល់កិច្ចការពារ ( PSF ) ដើម្បីជួយចេញចំណាយផ្សេងៗលើវិធានការការពារ ក្នុងការលើកគម្រោងកៀងគរថវិកាជាទៀងទាត់របស់ខ្លួន។

អង្គការអ្នកការពារអន្តរជាតិ ( Protection International ) ជាសមាជិកយន្តការសហភាពអឺរ៉ុប ProtectDefenders.eu.

ទូរស័ព្ទ៖ + 32 2 609 4405

គេហទំព័រ៖ https://protectioninternational.org

## ៣. អ្នកការពារសិទ្ធិមនុស្សជួរមុខ ( Front Line Defenders )

អ្នកការពារសិទ្ធិមនុស្សជួរមុខ គឺជាអង្គការអ្នកការពារសិទ្ធិមនុស្សជួរមុខមួយដែលមានគោលបំណងការពារអ្នកការពារសិទ្ធិអង្គការអ្នកការពារសិទ្ធិមនុស្សជួរមុខ មនុស្សដែលស្ថិតក្រោមហានិភ័យ។ អង្គការអ្នកការពារសិទ្ធិមនុស្សជួរមុខ ដោះស្រាយតម្រូវការផ្សេងៗផ្នែកការពារសិទ្ធិមនុស្ស ដែលកំណត់ដោយអ្នកការពារសិទ្ធិមនុស្សខ្លួនឯង។

អង្គការអ្នកការពារសិទ្ធិនុស្សជួរមុខ អ្នកការពារសិទ្ធិមនុស្សជួរមុខ ជាសមាជិកយន្តការសហភាពអឺរ៉ុប ProtectDefenders.eu.

ទូរស័ព្ទ៖ + 353 1 210 0489 ( ទូរស័ព្ទបន្ទាន់ ២៤ ម៉ោង ស្រមាប់អ្នកការពារសិទ្ធិមនុស្ស ដែលប្រតិបត្តិការជាភាសាអារ៉ាប់ អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ )
អ៊ីមែល៖ info@frontlinedefenders.org
គេហទំព័រ៖ www.frontlinedefenders.org

## ៤. អង្គការសហព័ន្ធអន្តរជាតិ សម្រាប់សិទ្ធិមនុស្ស ( FIDH )

អង្គការសហព័ន្ធអន្តរជាតិ សម្រាប់សិទ្ធិមនុស្ស ( FIDH ) ប្រតិបត្តិការលើយន្តការផ្តល់ជំនួយជាសាធារណៈ ដើម្បីពង្រើង និងធ្វើឲ្យមាននិរន្តរភាពដលគម្រោងផ្តួចផ្តើមដែលមានលក្ខណៈរសើបដោយអង្គការអ្នកការពារសិទ្ធិមនុស្សក្នុងស្រុក ដូចបានផ្សព្វផ្សាយក្នុងគេហទំព័រ និងការិយាល័យថ្នាក់តំបន់របស់ខ្លួន។ មានទីតាំងសម្រាប់អ្នកការពារសិទ្ធិមនុស្សជួបពិគ្រោះយោបល់។

អង្គការសហព័ន្ធអន្តរជាតិ សម្រាប់សិទ្ធិមនុស្ស ( FIDH ) ជាសមាជិកយន្តការសហភាពអឺរ៉ុប ProtectDefenders.eu.

ទូរស័ព្ទ៖ + 33 1 43 555 505 ( FIDH )
+ 41 22 8094 939 ( OMCT )
អ៊ីមែល៖ Appeals@fidh-omct.org
គេហទំព័រ៖ www.fidh.org

## ៥. អង្គការ OMCT SOS-បណ្តាញអំពើទារុណកម្ម

អង្គការ OMCT ផ្តល់ការគាំទ្រដល់អង្គការសិទ្ធិមនុស្សក្នុងស្រុក ពីគ្រប់តំបន់នៅក្នុងពិភពលោក ក្នុងគោលបំណងជួយឲ្យពួកគេអាចបង្រួមសកម្មភាពប្រតិបត្តិឲ្យបានរឹងមាំ។

អង្គការ OMCT ជាសមាជិកយន្តការសហភាពអឺរ៉ុប ProtectDefenders.eu.

ទូរស័ព្ទ៖ + 41 22 809 4939
អ៊ីមែល៖ omct(@)omct.org
គេហទំព័រ៖ www.omct.org

## ៦. អង្គការអ្នករាយការណ៍ឥតព្រំដែន ( Reporters without Borders )

អង្គការអ្នករាយការណ៍ឥតព្រំដែន (RSF ) គាំទ្រដល់អ្នកសារព័ត៌មាន និងអ្នកសរសេរប្លុកក្នុងវិស័យ មានដូចជា ការរៀបចំយុទ្ធនាការផ្សេងៗ ការផ្តល់ជំនួយផ្នែកច្បាប់ ជំនួយហិរញ្ញវត្ថុ និងបរិក្ខាកិច្ចការពារ ការបណ្តុះបណ្តាល ព្រមទាំងជំនួយផ្នែកសុវត្ថិភាពឌីជីថល ផងដែរ។

អង្គការអ្នករាយការណ៍ឥតព្រំដែន ( RSF ) ជាសមាជិកយន្តការសហភាពអឺរ៉ុប Protect Defenders.eu.

ទូរស័ព្ទ៖ + 33 1 4483 6056
អ៊ីមែល៖ assistance@rsf.org
គេហទំព័រ៖ https://rsf.org

# ៣. យន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ

## ១. អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស

អ្នករាយការណ៍ពិសេស គឺជាអ្នកជំនាញឯករាជ្យដែលស្វែងរកពិនិត្យមើល និងឆ្លើយតបចំពោះព័ត៌មានស្ដីពីស្ថានភាពសិទ្ធិមនុស្សនានារបស់អ្នកការពារសិទ្ធិមនុស្ស ធ្វើការសន្ទនាជាមួយរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានាផ្ដល់អនុសាសន៍អំពីយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពដើម្បីការពារអ្នកការពារសិទ្ធិមនុស្ស ព្រមទាំងបន្តតាមដានការអនុវត្តទៅលើអនុសាសន៍។

## ២. អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

អ្នករាយការណ៍ពិសេស គឺជាអ្នកជំនាញឯករាជ្យ ដែលមានភារកិច្ចធ្វើការវាយតម្លៃអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ធ្វើរបាយការណ៍ជាសាធារណៈអំពីស្ថានភាពសិទ្ធិមនុស្ស និងធ្វើការជាមួយរដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកផ្សេងទៀត ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស។ អ្នករាយការណ៍ពិសេសបំពេញបេសកកម្មជាទៀងទាត់នៅកម្ពុជា និងធ្វើរបាយការណ៍ប្រចាំឆ្នាំទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។

## ៣. យន្តការបណ្ដឹងអន្តរជាតិ

- **លិខិតឆ្លងឆ្លើយជាមួយនីតិវិធីពិសេស**

  - ការឆ្លងឆ្លើយ គឺជាលិខិតដែលនីតិវិធីពិសេស បញ្ជូនទៅកាន់រដ្ឋាភិបាលនានា និងអ្នកពាក់ព័ន្ធផ្សេងៗ ឧទា. ដូចជាអង្គការអន្តររដ្ឋាភិបាលធុរកិច្ច។ល។ ដែលអ្នករាយការណ៍ពិសេសធ្វើរបាយការណ៍អំពីការចោទប្រកាន់ផ្សេងៗដែលគាត់បានទទួលពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិមនុស្ស ។
  - លិខិតនេះ ក៏អាចពាក់ព័ន្ធនឹងករណីបុគ្គលម្នាក់ៗ ឬសហគមន៍ជាក់លាក់ណាមួយ វាក៏អាចពាក់ព័ន្ធនឹងលំនាំជាទូទៅនៃការរំលោភសិទ្ធិមនុស្ស ឬវាក៏អាចពាក់ព័ន្ធនឹងខ្លឹមសារនៃពង្រាងច្បាប់ ឬច្បាប់ដែលមានស្រាប់ គោលនយោបាយ ឬការអនុវត្តដែលមិនស្របតាមស្តង់ដារសិទ្ធិមនុស្ស។
  - បុគ្គលណាក្រុមណា អង្គការសង្គមស៊ីវិលណា អង្គភាពអន្តររដ្ឋាភិបាលណា ឬ ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិណាក៏ដោយ ក៏អាចដាក់ព័ត៌មានទៅកាន់នីតិវិធីពិសេសបានដែរ។ បុគ្គលដែលមានបំណងចង់ដាក់បណ្ដឹង អាចប្រើប្រាស់ទម្រង់/កម្រងសំណួរតាមប្រព័ន្ធអ៊ីនធឺណិតនេះ “Online submission to special procedures“។

ការដាក់នេះ ក៏អាចធ្វើបានដោយមិនចាំបាច់ធ្វើតាមកម្រងសំណួរ និងអាចធ្វើតាមរយៈអ៊ីមែលទៅកាន់ urgent-action@ohchr.org ឬតាមរយៈការផ្ញើតាមប្រៃសណីយ៍ផងដែរ។

ផ្ញើទៅ OHCHR-UNOG
8-14 Avenue de la Paix,
1211 Geneva 10
Switzerland

តាមប្រព័ន្ធអ៊ីនធឺណិត https://spsubmission.ohchr.org/

អ៊ីមែល urgent-action@ohchr.org

គេហទំព័រ៖ https://www.ohchr.org/EN/HRBodies/SP/Pages/Welcomepage.aspx

## នីតិវិធីនៃការដាក់បណ្ដឹងទៅកាន់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស

- បណ្ដឹងរបស់បុគ្គល ឬចេញពីបុគ្គលណាម្នាក់ អាចធ្វើបានក្រោមលក្ខខណ្ឌមួយចំនួនទៅកាន់ស្ថាប័នជំនាញឯករាជ្យ ដែលតាមដានសន្ធិសញ្ញា ដូចជា អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងទៅលើស្ត្រីភេទ (CEDAW) និងពិធីសារបន្ថែមនៃអនុសញ្ញានេះ។
- អាចមានការផ្ដួចផ្ដើមឲ្យមានការស៊ើបអង្កេត ប្រសិនបើមានព័ត៌មានដែលជឿជាក់បានថា មានការរំលោភបំពានធ្ងន់ធ្ងរ ឬជាប្រព័ន្ធប្រព្រឹត្តដោយរដ្ឋជាភាគី អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំនឹងស្ត្រីភេទ (CEDAW)។

ផ្ញើទៅ Petitions and Inquiries Section
Office of the High Commissioner for Human Rights
United Nations Office at Geneva
1211 Geneva 10, Switzerland

អ៊ីម៉ែល petitions@ohchr.org

គេហទំព័រ៖ https://www.ohchr.org/EN/HRBodies/Pages/TreatyBodies.aspx

## នីតិវិធីនៃការដាក់បណ្ដឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស

- បុគ្គល ក្រុម ឬអង្គការមិនមែនរដ្ឋាភិបាលនានា ដែលអះអាងថាជាជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស ឬដែលបានឃើញនិងដឹងដោយផ្ទាល់អំពីការរំលោភបំពានបែបនេះអាចដាក់បណ្ដឹងទៅកាន់នីតិវិធីទទួលបណ្ដឹងរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីបណ្ដឹងនោះ ត្រូវបំពេញត្រឹមត្រូវតាមលក្ខណៈវិនិច្ឆ័យមួយចំនួនដូចខាងក្រោមនេះ។

អ៊ីម៉ែល៖ CP@ohchr.org

គេហទំព័រ៖ http://www.ohchr.org/EN/HRBodies/HRC/Pages/HRCIndex.aspx

# ៤. ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា


| | |
|---|---|
| ទូរស័ព្ទ៖ | + 855 ( 0 ) 23 987 671 or 672 |
| អាសយដ្ឋាន | ផ្ទះលេខ ៤, ផ្លូវ ២៧១<br>សង្កាត់ផ្សារដើមថ្កូវ<br>ខណ្ឌចំការមន, ប្រអប់សំបុត្រ P.O Box 108<br>ភ្នំពេញ កម្ពុជា |
| អ៊ីម៉ែល៖ | cambodia@ohchr.org |
| គេហទំព័រ៖ | http://cambodia.ohchr.org/ |

# ៥. រដ្ឋនានា និងអង្គការថ្នាក់តំបន់

## ១. សហភាពអឺរ៉ុប

អង្គការ ProtectDefenders.eu គឺជាយន្តការអ្នកការពារសិទ្ធិមនុស្សរបស់សហភាពអឺរ៉ុប ដែលបានបង្កើតឡើង ដើម្បីការពារដល់អ្នកការពារសិទ្ធិគ្រប់រូបដែលស្ថិតក្រោមហានិភ័យខ្ពស់ និងដែលកំពុងប្រឈមមុខនឹងស្ថានភាពលំបាកបំផុតនៅជុំវិញពិភពលោក។ កម្មវិធីផ្ដល់ជំនួយក្នុងគ្រាអាសន្ន ធានាថា អ្នកការពារសិទ្ធិមនុស្សទាំងនោះ អាចទទួលបាន និងអាចអនុវត្តវិធានការសុវត្ថិភាពបន្ទាន់ ក្នុងការការពារខ្លួនឯង ក្រុមគ្រួសារ និងការងាររបស់ពួកគេផ្ទាល់។

ទូរស័ព្ទ៖ + 353 1 21 00 489 ( ទូរស័ព្ទបន្ទាន់ ២៤ ម៉ោង សម្រាប់អ្នកការពារសិទ្ធិមនុស្សដែលប្រតិបត្តិការជាភាសាអារ៉ាប់ អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ )

គេហទំព័រ៖ www.protectdefenders.eu

## ២. ប្រទេសហូឡង់

មូលនិធិសិទ្ធិមនុស្ស ( MRF ) គាំទ្រដល់អង្គការដែលធ្វើការសម្រាប់សិទ្ធិមនុស្ស ទូទាំងពិភពលោក

ទូរស័ព្ទ៖ + 31 77 465 6767.

អ៊ីមែល៖ MRF2017-2020@minbuza.nl ឬ DMM@minbuza.nl

គេហទំព័រ៖ www.government.nl

# ឧបសម្ព័ន្ធ

## សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើសកម្មភាពរបស់សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋាន

# ឧបសម្ព័ន្ធ

## សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ស្តីពីការធ្វើសកម្មភាពរបស់សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ២០០៦ សជណ

ថ្ងៃ ចន្ទ ៥រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៨

**ជូនចំពោះ**

**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**
**និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត**

**កម្មវត្ថុ** ៖ ស្តីពីការធ្វើសកម្មភាពរបស់សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋាន។

**យោង** ៖ សេចក្តីណែនាំលេខ០៤០ សណន ចុះថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ជ្រាបថា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងសហគមន៍នានានៅមូលដ្ឋាន ក្រសួងមហាផ្ទៃបានដាក់ចេញនូវសេចក្តីណែនាំ០៤០ សណន ចុះថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨។ ក្នុងន័យនេះ សមាគម អង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ ព្រមទាំងសហគមន៍នានានៅមូលដ្ឋានមានសិទ្ធិសេរីភាពពេញលេញក្នុងការធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ព្រមទាំងលក្ខន្តិកៈរបស់ខ្លួនដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយពុំចាំបាច់ជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានក្នុងរយៈពេល ០៣ថ្ងៃ មុនពេលចាប់ផ្តើមធ្វើសកម្មភាពដូចមុននោះឡើយ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម ឯកឧត្តម លោកជំទាវ ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ ៖ [illegible]
ទូរសារ ៖ [illegible] e-mail: moi@interior.gov.kh web: www.interior.gov.kh

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

@OHCHRCambodia
@OHCHR_Cambodia
UNCOHCHR
www.cambodia.ohchr.org
cambodia@ohchr.org